# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Oct-21, 08:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើរបស់ មាស មុត សុំបញ្ចប់សំណុំរឿង ០០៣

---

**ដាក់ដោយ ÷**

**សហមេធាវី ៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន ÷**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ៖**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងរឿងក្តី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមយុត្តាធិការនៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការ"ធានាសច្ចភាពផ្លូវច្បាប់ និង អវសានកិច្ច" និង "ក្នុងការផ្តល់ឧបាស្រ័យតាមផ្លូវច្បាប់ ហើយនិងក្នុងការកំណត់អវសាននៃរឿងក្តី ដែលលក្ខន្តិកៈ ឬ ច្បាប់ចែងមិនច្បាស់លាស់"[1] តាមរយៈនេះ ស្នើសុំអង្គជំនុំជម្រះឱ្យបញ្ចប់សំណុំរឿង ០០៣ និង បង្គាប់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") ឱ្យដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ស្របទៅតាមសេចក្តីសម្រេចរបស់ខ្លួន ដែលបញ្ចប់សំណុំរឿង ០០៤/២។

## I. សាវតា

១. លោក មាស មុត បានស្ថិតក្រោមការស៊ើបអង្កេតអស់រយៈពេល ១៣ ឆ្នាំមកហើយ។ ស.ច.ស. ជាតិម្នាក់ និង អន្តរជាតិប្រាំនាក់ បានស៊ើបអង្កេតរឿងក្តីនេះ។ នៅពេលបញ្ចប់ការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ.") យូ ប៊ុនឡេង និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") Michael Bohlander ដែលជ្រើសមិនប្តឹងទៅអង្គបុរេជំនុំជម្រះ ("អ.ប.ជ.") ពីការខ្វែងយោបល់គ្នារបស់ពួកគាត់ បានចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា នៅក្នុងពេលដំណាលគ្នានេះ បញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ និង លើកលែងចោទប្រកាន់។ អ.ប.ជ. បានប្រកាសថា ការចេញដីកាដំណោះស្រាយទាំងនោះ គឺខុសច្បាប់ ដូចដែលពួកគាត់បានអនុវត្តនៅក្នុងរឿងក្តី ០០៤/២ ដែរ។ អ.ប.ជ. មិនបានប្រើប្រាស់ឧបាស្រ័យចំពោះដីកាដំណោះស្រាយខុសច្បាប់ ដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ នៅពេលបញ្ចប់រឿងក្តី ០០៤/២ ឡើយ ផ្ទុយទៅវិញបែរជាបានបង្គាប់ឱ្យបញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ និង បញ្ជូនរឿងក្តីទៅជំនុំជម្រះ។ នៅពេលស្នើសុំឱ្យបញ្ជូនរឿងក្តី ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ.") ស.ច.ស. បានកំណត់ថា អ.ប.ជ. នៅតែទទួលពិនិត្យ និង ទទួលខុសត្រូវចំពោះដំណើរការនីតិវិធីមុនពេលជំនុំជម្រះ។ នៅពេលភាគីងាកទៅរក អ.ប.ជ. ម្តងទៀត ដើម្បីបញ្ចប់ដំណើរការនីតិវិធីមុនពេលជំនុំជម្រះ អ.ប.ជ. បានប្រកាសថា ខ្លួនបានបំពេញភារកិច្ចតាមផ្លូវតុលាការរួចរាល់ហើយ ហើយថា ស.ច.ស. ត្រូវទទួលខុសត្រូវលើការបន្តដំណើរការរឿងក្តី ស្របតាមសេចក្តីពិចារណាជាឯកច្ឆន្ទរបស់ អ.ប.ជ.។ ស.ច.ស. ពិចារណាថា រឿងក្តី ០០៣ គឺដល់ពេលបញ្ចប់ហើយ ដោយទុកឱ្យសហ

[1] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/០២") កថាខណ្ឌ ៦៤-៦៥។

ព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") ប្រកាសថា តើគាត់មានបំណងប្ដឹងទៅអង្គជំនុំជម្រះតុលាការកំពូល "ស្នើសុំបញ្ចប់ដូចក្នុងរឿងក្ដី ០០៤/២" ដែរឬទេ[2]។

២. ***សហព្រះរាជអាជ្ញាមិនបានព្រមព្រៀងគ្នាទៅលើបញ្ហាថា តើរឿងក្ដី ០០៣ គួរត្រូវបានចោទប្រកាន់ទោសដែរឬទេ***។ នៅខែវិច្ឆិកា ឆ្នាំ ២០០៨ ស.ព.អ. បានប្ដឹងទៅ អ.ប.ជ. ឱ្យពិនិត្យលើការខ្វែងយោបល់គ្នាមួយ ដោយថ្លែងថា គាត់មានបំណងដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ទាក់ទងទៅនឹងអ្វីដែលនឹងក្លាយទៅជារឿងក្ដី ០០៣ និង ០០៤[3]។ សមភាគីជាតិរបស់គាត់ គឺសហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ.") បាន"ជំទាស់នឹងការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្ម ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី"[4] ដោយពិចារណាថា អង្គហេតុនៃរឿងក្ដី ០០៣ ត្រូវបានគ្របដណ្ដប់រួច ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងរឿងក្ដី ០០២ ហើយថា លោក មាស មុត និង លោក ស៊ូ ម៉េត (ដែលបានទទួលមរណភាពនៅឆ្នាំ ២០១៥)[5] "មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ពីព្រោះពួកគាត់មានតួនាទីទាប ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និង ថា "សន្តិភាព ស្ថេរភាព និង ការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺជាតឹកតាងប្រឆាំងទៅនឹងការផ្ដួចផ្ដើមគំនិតថ្មីក្នុងការចោទប្រកាន់"[6]។

៣. ***ចៅក្រមនៃ អ.ប.ជ. មិនបានព្រមព្រៀងគ្នាទៅលើថា តើរឿងក្ដី ០០៣ គួរត្រូវបានចោទប្រកាន់ទោសដែរឬទេ***។ អ.ប.ជ. មិនអាចទទួលសំឡេងភាគច្រើនលើសលុបលើការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញានោះទេ[7]។ ចៅក្រមជាតិនៃ អ.ប.ជ. បានយល់ស្របជាមួយ ស.ព.ជ. ដែលថា

---

[2] ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D273 ("ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣") កថាខណ្ឌ ៧។

[3] អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នាស្របតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ ១ កថាខណ្ឌ ២។

[4] *ដូចខាងលើ* កថាខណ្ឌ ១២០។

[5] ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D86/3។

[6] ឧបសម្ព័ន្ធ ១៖ សំណៅសាធារណៈមានកោសលុបនៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ២៩-៣២។

[7] *ដូចខាងលើ* កថាខណ្ឌ ៤៥។

អង្គហេតុនៃរឿងក្តី ០០៣ ត្រូវបានគ្របដណ្តប់ដោយរឿងក្តី ០០២[8] និង បានពិចារណាថា ស.ព.អ. បានបើកកិច្ចស៊ើបអង្កេតជាឯកតោភាគី ដោយមិនបានជូនដំណឹងដល់ ស.ព.ជ.[9]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. មិនបានយល់ស្របទៅនឹងការវាយតម្លៃរបស់ ស.ព.ជ. ចំពោះការបំពេញកិច្ចស៊ើបអង្កេតបឋមដោយ ស.ព.អ. ទេ និង បានយល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងរឿងក្តី ០០៣ សំដៅទៅរកអង្គហេតុថ្មីៗបន្ថែមពីលើអង្គហេតុដែលត្រួតគ្នាក្នុងរឿងក្តី ០០២[10]។ ដោយសារថា អ.ប.ជ. ខកខានមិនអាចទទួលសំឡេងភាគច្រើនលើសលុប នោះការស៊ើបអង្កេតនៅតែបន្តដំណើរការ[11] ហើយនៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ស.ព.អ. ស្តីទី William Smith បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងរឿងក្តី ០០៣[12]។

៤. ***ស.ច.ស. ចាប់ផ្តើមកិច្ចស៊ើបអង្កេត។*** ស.ច.ស.ជ. យូ ប៊ុនឡេង និង ស.ច.ស.អ. Marcel Lemonde ជា ស.ច.ស.អ. ដំបូងគេបង្អស់របស់ អ.វ.ត.ក. បានចាប់ផ្តើមកិច្ចស៊ើបអង្កេត និងបង្កើតផែនការការងារលម្អិតមួយ[13]។ ស.ច.ស.ជ. និង ស.ច.ស.អ. Lemonde បានស៊ើបអង្កេតលើឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម អស់រយៈពេលជាងពីរឆ្នាំ ដើម្បីកំណត់ថាតើអ្នកដែលត្រូវបានស៊ើបអង្កេត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ[14]។ មុនពេលដែល ស.ច.ស.អ. Lemonde បានលាលែងពីតំណែង "ទៅរៀបចំ

[8] *ដូចខាងលើ* យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៧, ៣០។

[9] *ដូចខាងលើ* យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ១៨។

[10] *ដូចខាងលើ* យោបល់របស់ចៅក្រម Downing និង ចៅក្រម Lahuis កថាខណ្ឌ ៤, ២២។

[11] *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ២០០៣) ("កិច្ចព្រមព្រៀង") មាត្រា ៧(៤)។ *សូមមើលផងដែរ* វិធាន ៧២(៤) នៃវិធានផ្ទៃក្នុង។

[12] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[13] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ២៦ (ខែមិថុនា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/The%20Court%20Report%20%5BJune%202010%5D%20FINAL.pdf.។

[14] ស.ច.ស. បានប្តឹងស៊ើបអង្កេតទៅលើរឿងក្តី ០០១ និង ០០២ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧។ *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ៤។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ៣។

ផែនការរយៈពេលវែងផ្សេងទៀត”[15] ស.ច.ស. បានប្រមូលផ្តុំភស្តុតាងជាង ១.១៣០ សំណៅនៅក្នុងរឿងក្តី ០០៣[16]។

៥. ***ការស៊ើបអង្កេតបញ្ចប់។*** នៅពេល ស.ច.ស.អ. Siegfried Blunk បានចូលកាន់តំណែងបន្ទាប់ពី ស.ច.ស.អ. Lemonde នៅថ្ងៃ ១ ខែធ្នូ ឆ្នាំ ២០១០[17] គាត់បានបន្តការស៊ើបអង្កេតជាមួយ ស.ច.ស.ជ.[18] ដោយផ្តោតលើការកំណត់ថាតើលោក មាស មុត ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬទេ[19]។ ស.ច.ស. “បានបង្កើតក្រុមការងាររួមគ្នា”[20] “បានយល់ស្របគ្នាលើវិធីសាស្ត្រនៃការស៊ើបអង្កេត”[21] និង បានស៊ើបអង្កេត “ដោយរលូន និង យល់ស្របគ្នាទាំងស្រុង”[22]។ បន្ទាប់ពីការស៊ើបអង្កេតបានរយៈពេលចំនួន ២០ ខែ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ស.ច.ស. បានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ដោយការ“យល់ស្របគ្នាជាឯកច្ឆន្ទ” ថាមិនចោទប្រកាន់លោក

[15] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ២៩ (ខែកញ្ញា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/Court_Report_September2010.pdf។ *សូមមើលផងដែរ* គេហទំព័ររបស់ អ.វ.ត.ក. *ចៅក្រម Marcel Lemonde* គេហទំព័រ https://www.eccc.gov.kh/en/person/judge-marcel-lemonde។

[16] តាមការស្រាវជ្រាវនៅលើប្រព័ន្ធ ZyLAB បានបង្ហាញថា ចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស.”) បានដាក់ឯកសារចំនួន ១.១៣៤ ជាភាសាអង់គ្លេស ខ្មែរ និង បារាំង ទៅក្នុងសំណុំរឿង។ *សូមមើលផងដែរ* ប្រព័ន្ធ ZyLAB “សំណុំរឿង៖ CF003” “កាលបរិច្ឆេទដាក់ឯកសារ៖ ចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០” និង “ភាគីដាក់ឯកសារ៖ ក.ស.ច.ស.”។ ឯកសារមួយចំនួនដែលបានដាក់នៅក្នុងសំណុំរឿងក្នុងកំឡុងពេលនោះ អាចជាន់គ្នា។

[17] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ គេហទំព័រ https://www.eccc.gov.kh/en/articles/dr-siegfried-blunk-appointed-new-international-co-investigating-judge។

[18] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016%3A37/E189_3_1_1.1.3_EN.pdf។

[19] របាយការណ៍តុលាការរបស់ អ.វ.ត.ក៖ លេខ ៣៣ (ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ គេហទំព័រhttps://www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[20] របាយការណ៍តុលាការរបស់ អ.វ.ត.ក៖ លេខ ៣៣ (ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ គេហទំព័រhttps://www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[21] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D266 (“ដីកាសម្រេចលើកលែងចោទប្រកាន់”) កថាខណ្ឌ ៤៨។

[22] *ដូចខាងលើ* កថាខណ្ឌ ៤១។

មាស មុត នោះទេ[23]។ បន្ទាប់ពីមានសេចក្ដីថ្លែងនៅក្នុងសារព័ត៌មានបានចោទសួរពីភាពឯករាជ្យ និង សុចរិតភាពរបស់ ស.ច.ស.អ. Blunk គាត់ក៏បានលាលែងពីតំណែង[24]។

៦. ***ការស៊ើបអង្កេតបើកឡើងវិញ។*** បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ("ស.ច.ស.អ.ប.") Laurent Kasper-Ansermet បានចូលកាន់តំណែង ដែលមិនធ្លាប់បានស្បថជា ស.ច.ស.អ.[25]។ គាត់បានបើកកិច្ចស៊ើបសួរឡើងវិញដោយឯកតោភាគី[26] ដោយសារតែខ្លាចថា ស.ច.ស.ជ. នឹងចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដែលបានព្រាងរួមគ្នាជាមួយ ស.ច.ស.អ. Blunk បើទោះជាគាត់បានទទួលស្គាល់ថា គាត់មិនបានពិនិត្យមើលសំណុំរឿងក្តី និង ទោះបីជាមានការដាស់តឿនរបស់ ស.ច.ស.ជ. ឱ្យគាត់ពិនិត្យភស្តុតាង មុនពេល"មានចំណាត់ការតាមបែបប្រញាប់ប្រញាល់" ណាមួយក៏ដោយ[27]។ ប្រាំខែបន្ទាប់ពីការបើកកិច្ចស៊ើបសួរឡើងវិញ ស.ច.ស.អ.ប. Kasper-Ansermet បានលាលែងពីតំណែង[28]។

៧. ***លោក មាស មុត ត្រូវបានចោទប្រកាន់។*** ស.ច.ស.ជ. បានបដិសេធមិនព្រមចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដោយរង់ចាំសមភាគីអន្តរជាតិថ្មីរបស់គាត់គឺ ស.ច.ស.អ. Mark Harmon ឱ្យយល់

---

[23] សេចក្តីជូនដំណឹងស្តីពីការបិទការស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៣។

[24] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016%3A37/E189_3_1_1.1.3_EN.pdf។ ស.ច.ស.អ. Blunk បានលាលែងពីតំណែង ដោយមានអនុភាពចាប់ពីនៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១១។ *សូមមើល* គេហទំព័ររបស់ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk* គេហទំព័រ https://www.eccc.gov.kh/en/person/dr-siegfried-blunk។

[25] សេចក្តីប្រកាសព័ត៌មានរបស់ អ.ស.ប.៖ *សេចក្តីថ្លែងការណ៍ក្នុងនាមអ្នកនាំពាក្យរបស់អគ្គលេខាធិការស្តីពីប្រទេសកម្ពុជា* ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២ គេហទំព័រ https://www.un.org/sg/en/content/sg/statement/2012-01-20/statement-attributable-spokesperson-secretary-general-cambodia។

[26] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D28។

[27] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/node/17495។

[28] ស.ច.ស.អ.ប. Kasper-Ansermet បានលាលែងពីតំណែង ដោយមានអនុភាពចាប់ពីនៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០១២។ *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/press-release-international-reserve-co-investigating-judge។

ច្បាស់ពីសំណុំរឿងជាមុនសិន[29] ពិភាក្សាអំពីស្ថានភាពនៃការស៊ើបអង្កេត និង ចុះកំណត់ហេតុការខ្វែងយោបល់គ្នាផ្ទៃក្នុង នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣[30]។ បន្ទាប់ពីមានការខ្វែងយោបល់គ្នា ស.ច.ស.ជ. បានចេញដីកាបញ្ជូនរឿងទៅពិនិត្យរបស់ខ្លួន ដោយពិចារណាថា ការស៊ើបអង្កេតបានបញ្ចប់សព្វគ្រប់តាំងពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[31]។ ទន្ទឹមនឹងនោះ ស.ច.ស.អ. Harmon បានបន្តការស៊ើបអង្កេត[32] ដោយសារតែ តាមការយល់របស់គាត់គឺ ស.ច.ស. មាន "ឆន្ទានុសិទ្ធិសម្រេចដោយឯករាជ្យ នៅពេលណាដែលខ្លួនពិចារណាថា ការស៊ើបអង្កេតត្រូវបានបញ្ចប់"[33]។ ក្រោយមកនៅពេលដែល ស.ច.ស.ជ. បានផ្ញើរអនុស្សរណៈមួយជូនដល់ ស.ច.ស.អ. Harmon "ទាក់ទងនឹងការបិទការស៊ើបអង្កេត និង លទ្ធភាពរបស់ [ស.ច.ស.អ.] ក្នុងការប្តឹងឧទ្ធរណ៍ទៅកាន់ [អ.ប.ជ.] ដោយការស្នើសុំឱ្យបើកការស៊ើបអង្កេតឡើងវិញ"[34] ស.ច.ស.អ. Harmon មិនបានឆ្លើយតប និង បានបន្តការស៊ើបអង្កេត និង ប្រមូលភស្តុតាង[35]។ នៅទីបំផុត គាត់ក៏បានចោទប្រកាន់លោក មាស

---

[29] ស.ច.ស.អ Mark Harmon បានស្បថចូលកាន់តំណែងជា ស.ច.ស.អ. ទីបួន នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១២។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ លោក *Mark Harmon ស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១២ គេហទំព័រ https://www.eccc.gov.kh/en/articles/mark-harmon-sworn-international-co-investigating-judge។

[30] *សូមមើល* ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិកនៃសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០។

[31] ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D52។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីថ្លែងការណ៍ព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣* ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ គេហទំព័រ https://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-003។

[32] *សូមមើល* ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១២។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D54។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D55។

[33] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[34] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៤។

[35] *ដូចខាងលើ* កថាខណ្ឌ ៤៤។

មុត[36] ក្នុងរយៈពេលបួនខែ មុនពេលលាលែងពីមុខតំណែង "ដោយមូលហេតុផ្ទាល់ខ្លួន"[37]។

៨. ***ស.ច.ស.អ. ចុងក្រោយបង្អស់ ស្បថចូលកាន់តំណែង។*** បន្ទាប់ពីបានស្បថចូលកាន់តំណែង នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ស.ច.ស.អ. Michael Bohlander ដែលជា ស.ច.ស.អ. ចុងក្រោយគេបង្អស់នៃ អ.វ.ត.ក. បានសិក្សាសំណុំរឿង បានធ្វើការស៊ើបអង្កេត និង ប្រមូលភស្តុតាង[38] បានចេញជាថ្មីនូវសេចក្តីសម្រេចទាំងឡាយ ដែល ស.ច.ស.អ. Harmon[39] បានចេញ បានលុបចោទបទចោទខ្លះរបស់ ស.ច.ស.អ. Harmon[40] និង បានចោទប្រកាន់លោក មាស មុត ពីបទឧក្រិដ្ឋកម្មមួយចំនួនបន្ថែមទៀត[41]។ ស.ច.ស.ជ. បានរង់ចាំ ស.ច.ស.អ. Bohlander បញ្ចប់ការស៊ើបអង្កេតរបស់គាត់។

៩. ***វិបត្តិថវិកាគម្រាមកំហែងដល់សុចរិតភាពនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក.។*** នៅពេលដែលស្ថានភាពថវិការបស់តុលាការឈានដល់ "ចំណុចវិបត្តិ" នៅពាក់កណ្តាលឆ្នាំ ២០១៧ ស.ច.ស. បានគ្រោងនឹងផ្អាកនីតិវិធីជាអចិន្ត្រៃយ៍[42] ដោយយល់ឃើញថា វាមិនស្របតាមតម្រូវការជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ និង នីតិរដ្ឋ ក្នុងការចេញដីកាដំណោះស្រាយមួយ ជាពិសេសដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាច"តាមលងបន្ទាចជនត្រូវចោទ" ប្រសិនបើមិនមានថវិកាគ្រប់គ្រាន់សម្រាប់ឱ្យ អ.ប.ជ. ពិនិត្យលើបណ្តឹងឧទ្ធរណ៍ "ហើយ តទៅមុខ នៅតែមានមន្ទិលយ៉ាង

---

[36] ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D128.1។

[37] ស.ច.ស.អ. Harmon បានលាលែងពីតំណែង ដោយមានអានុភាពចាប់ពីនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *ចៅក្រម Harmon* ប្រកាសលាលែងពីតំណែង ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៥ គេហទំព័រ https://www.eccc.gov.kh/en/articles/judge-harmon-announces-his-resignation។

[38] *សូមមើល ឧទា.* ការពន្យារពេលដីកាចាត់ឱ្យស៊ើបសួរ D59 ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D59.13។ ការពន្យារពេលដីកាចាត់ឱ្យស៊ើបសួរ D89 ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D89.11។

[39] សេចក្តីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្តីពី ការចេញសាឡើងវិញនូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ឬ បន្ទាប់ពីកាលបរិច្ឆេទនេះ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D149។ *សូមមើល ឧទា.* ដីកាសម្រេចសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D120/3។

[40] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174 ទំព័រ ១៥-១៦។

[41] *ដូចខាងលើ* ទំព័រ ១៤-១៥។

[42] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ១, ៧៥, ៨៤។

ខ្លាំងអំពីការចូលរួមរបស់ភាគីទាំងឡាយ នៅក្នុងសវនាការចំពោះមុខ [អ.ជ.ស.ដ.] ... និង អង្គជំនុំជម្រះតុលាការកំពូល”[43]។ ដោយមានការផ្តល់ថវិកាជាបន្ទាន់ ស.ច.ស. បានពន្យាពេលការផ្អាកកិច្ចនីតិវិធី ដោយរង់ចាំវឌ្ឍនភាពភាពទៅមុខទៀត ដោយត្រៀមចាត់វិធានការចាំបាច់ ប្រសិនបើឯករាជ្យភាពរបស់តុលាការ ភាពយុត្តិធម៌ និង សុចរិតភាពនៃដំណើរការនីតិវិធី រងការគម្រាមកំហែងនោះ[44]។

១០. ***ការស៊ើបអង្កេតបញ្ចប់ដោយមានតម្រុយមួយ។*** បន្ទាប់ពីបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ និង ចម្លើយរបស់មេធាវីការពារក្តី ស.ច.ស. បានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ថា ពួកគាត់បានពិចារណាទៅលើដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា ដោយផ្អែកលើការខ្វែងយោបល់គ្នាមួយ ដែលអាចធ្វើបាន អនុលោមតាមក្របខណ្ឌរបស់ អ.វ.ត.ក. “និង អំពីផលវិបាកដែលទំនងជាកើតមានសម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង”[45]។ តាមការយល់ឃើញរបស់ពួកគាត់ វិធានទាំងនេះមិនតម្រូវឱ្យសហព្រះរាជអាជ្ញា ឬ ស.ច.ស. ប្តឹងទៅ អ.ប.ជ. ឱ្យពិនិត្យលើការខ្វែងយោបល់គ្នាទេ ដូច្នេះ អនុញ្ញាតឱ្យពួកគាត់ដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ពីគ្នា និង ចេញដីកាដំណោះស្រាយដាច់ពីគ្នាបាន[46]។ ពុំមានបណ្តឹងឧទ្ធរណ៍ណាមួយត្រូវបានដាក់ជំទាស់នឹងសេចក្តីសម្រេចរបស់ ស.ច.ស. នោះទេ។ សូម្បីតែ អ.ប.ជ. ដែលត្រូវបានជូនដំណឹងជាសាធារណៈអំពីសេចក្តីសម្រេចនេះ ក៏មិនបានបង្គាប់ឱ្យ ស.ច.ស. ចេញដីកាដំណោះស្រាយតែមួយ ឬ ផ្តល់យោបល់ណែនាំនោះឡើយ។

---

[43] *ដូចខាងលើ* កថាខណ្ឌ ៥៣-៥៤។

[44] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ៦៣, ៦៧។

[45] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 កថាខណ្ឌ ១៩។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៤។

[46] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D353/1 កថាខណ្ឌ ៣៤។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៤។

១១. ***ស.ច.ស. ចេញដីកាដំណោះស្រាយរបស់ខ្លួន។*** ដូចដែលបានជូនដំណឹងដល់ភាគីនានា[47] នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ស.ច.ស. បានចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតរបស់ពួកគេ។ ស.ច.ស.ជ. បានសម្រេចលើកលែងចោទប្រកាន់ ដោយយល់ឃើញថាលោក មាស មុត មិនស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ពីព្រោះថា បើទោះបីជាគាត់មានតួនាទីច្រើនក៏ដោយ ក៏គាត់ "មិនមានអំណាចច្រើន" ហើយ "ការចូលរួមរបស់គាត់ មិនសកម្ម មិនជុំកំភួន និង មិនបានកៀកកិតនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ"[48]។ ស.ច.ស.អ. Bohlander បានយល់ឃើញផ្ទុយពីនេះ[49] ដោយចោទប្រកាន់បញ្ជូនលោក មាស មុត ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មជាតិ[50]។

១២. ***ភាគីទាំងឡាយប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។*** នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ ដែលបានដាក់កាលពីថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ មេធាវីការពារក្តី និង ស.ព.អ. បានយល់ស្របគ្នាថា ក្របខណ្ឌ អ.វ.ត.ក. អនុញ្ញាតឱ្យ ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា ដោយសារតែពាក្យពេចន៍ជាឆន្ទានុសិទ្ធិនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គោលការណ៍ណែនាំលើការបកស្រាយនៅក្នុងវិធាន ១(២) នៃវិធានផ្ទៃក្នុង និង ឋានៈស្មើគ្នារបស់ ស.ច.ស. លើការស៊ើបអង្កេត ទោះបីជាមានការមិនយល់ស្របគ្នាលើបញ្ហាថា តើដីកាដំណោះស្រាយណាមួយមានឧត្តមានុភាពក្នុងករណីដែលមិនអាចច្រានចោលដីកាដំណោះស្រាយណាមួយ ដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. ក៏ដោយ[51]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា៖ (ក) យន្តការដោះស្រាយជម្លោះតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបានឡើយ ដោយសារតែ ស.ច.ស. មិនបាន

---

[47] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[48] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[49] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០។

[50] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ ៤២២-៤៣១។

[51] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៣៤-៤៨។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.") កថាខណ្ឌ ១៩១-១៩៨។

បញ្ជូនការខ្វែងយោបល់គ្នាណាមួយទៅ អ.ប.ជ.[52] (ខ) វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តចំពោះបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយដែលផ្ទុយគ្នា ដោយសារតែវិធាននេះអនុវត្តតែចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយប៉ុណ្ណោះ[53] (គ) ស.ច.ស. ទាំងពីរ មានឋានៈស្មើគ្នា[54] និង (ឃ) លើកលែងតែ អ.ប.ជ. យល់ឃើញដោយសំឡេងភាគច្រើនលើសលុបថា ស.ច.ស.ជ. បានប្រព្រឹត្តកំហុស ឬ រំលោភបំពានលើកត្តាកំណត់ជាមូលដ្ឋាននៃការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គាត់ នោះដីកាសម្រេចលើកលែងចោទប្រកាន់មានឧត្តមានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*[55]។ ស.ព.អ បានលើកទឡ្ហីករណ៍ថា៖ (ក) វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺជា*ច្បាប់ពិសេស* ទាក់ទងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង មានឧត្តមានុភាពលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក), (ខ) ក្របខណ្ឌ អ.វ.ត.ក. ឆ្លុះបញ្ចាំង "គោលការណ៍ដែលថា ស.ច.ស. និង សហព្រះរាជអាជ្ញាអាចបំពេញកិច្ចដោយឯករាជ្យ ជម្រុញឱ្យដំណើរការនីតិវិធីទៅមុខ និង ដំណើរការនីតិវិធីបន្តទៅមុខ ក្នុងករណីការខ្វែងយោបល់គ្នាពុំអាចរកដំណោះស្រាយបាន" និង ដូច្នេះហើយគឺ (គ) អ.ជ.ស.ជ. ត្រូវតែទទួលរឿងក្ដីមកពិនិត្យ ប្រសិនបើ អ.ប.ជ. ខកខានមិនបានច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសំឡេងភាគច្រើនលើសលុបនោះ[56]។

១៣. ***ទឡ្ហីករណ៍ផ្ទាល់មាត់ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩។*** នៅថ្ងៃទីបីនៃសវនាការ ចៅក្រម Olivier Beauvallet បានចោទសួរទៅ ស.ព.អ. "ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាក្នុងពេលតែមួយ"[57]។ ស.ព.អ. បានលើកទឡ្ហីករណ៍ថា ការចេញដីកាដំណោះស្រាយពីរ អាចត្រូវអនុញ្ញាតបាន ដោយសារតែ "ការផ្លាស់ប្ដូរយន្តការខ្វែងយោបល់គ្នា ដែលបានអនុញ្ញាត ... ទៅជាយន្តការតម្រូវចាំបាច់" នឹងរំលោភបំពានទៅលើពាក្យពេចន៍ក្នុងកិច្ចព្រមព្រៀង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុង ហើយរឹតត្បិតដោយមិន

---

[52] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៥-៣៨។

[53] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-៤៦។

[54] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៤, ៣៧, ៤៥, ៦០, ៦៦។

[55] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៥០-៧២។

[56] បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ. កថាខណ្ឌ ១៩១-១៩៨។

[57] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១១.២៤.៤០-១១.២៨.៣៥។

ត្រឹមត្រូវទៅលើឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស."[58]។ ទោះបីជាមេធាវីការពារក្តីបានយល់ស្រប នឹង ស.ព.អ. នៅក្នុងបណ្តឹងឧទ្ធរណ៍លាយលក្ខណ៍អក្សររបស់ខ្លួនក្តី ក៏មេធាវីការពារក្តីបានស្នើសុំ ឱ្យពិចារណាថា ភាគីទាំងពីរអាចមានការភាន់ច្រឡំ៖ "បើយើងខុស ហើយបើ [ស.ច.ស.] បាន បំពេញកិច្ច *ហួសពីសមត្ថកិច្ច* នោះ គ្មានអ្វីអាចរារាំង [អ.ប.ជ.] មិនឱ្យបង្វិលបញ្ហាត្រឡប់មកវិញ ដោយបង្គាប់ឱ្យ ស.ច.ស. រួមបង្កើតឡើងវិញ និង ដោយមានការបង្គាប់ណែនាំឱ្យពួកគេចេញដីកាមួយ ឬ ក៏តាមលទ្ធភាពសម្រាប់ [អ.ប.ជ.] ដែលត្រូវចាត់ចែងដោយ [ខ្លួនឯងផ្ទាល់]"[59]។

១៤. ***អ.ប.ជ. ចេញសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៤/២។*** នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ មុនពេលសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ខ្វែងក្នុងរឿងក្តី ០០៣ អ.ប.ជ. បានចេញសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៤/២ ដោយប្រកាសថា "ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[60]។ បើទោះជាយ៉ាងនេះក្តី ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានពិនិត្យអង្គសេចក្តីឡើងវិញ និង ផ្តល់ការគាំទ្រដល់ដីកាដំណោះស្រាយតាមការជ្រើសរើសរបស់ពួកគាត់[61]។

១៥. ***អ.ប.ជ. បានចេញសេចក្តីណែនាំផ្ទុយគ្នា។*** នៅវេលានៃការខ្វែងយោបល់គ្នាដែលកើតមានក្រោយៗមកក្នុងរឿងក្តី ០០៤/២ ចៅក្រមនៃ អ.ប.ជ. បានចេញអនុស្សរណៈផ្ទុយគ្នាស្តីពីអានុភាពផ្លូវច្បាប់លើសេចក្តីពិចារណារបស់ខ្លួន៖

ក. នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន អ.ប.ជ. បានចេញអនុស្សរណៈអន្តរការិយាល័យមួយ ដោយថ្លែងថា មានតែសំអាងហេតុ និង ការចាត់ចែងរួមគ្នាទេ ទើបមានអានុភាពផ្លូវច្បាប់ ហើយថា ការជូនដំណឹងអំពីសេចក្តីពិចារណាទៅដល់

---

[58] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១១.២៨.៣៥-១១.៤០.៥៦។ *សូមមើលជាពិសេស ដូចខាងលើ* ម៉ោង ១១.៣៤.៥៦-១១.៣៩.៤២។

[59] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១២.០១.៣៤-១២.០៤.១៤។

[60] *រឿងក្តី* អោ អាន សំណុំរឿងលេខ 004/2/07-09-2009- អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 & D360/33 ("សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៤/២") ទំព័រ ៨៩។

[61] *ដូចខាងលើ* ទំព័រ ៨៩។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៧៣-៣០២, ៣០៤-៦៨៧, ទំព័រ ៣៨២។

អ.ជ.ស.ដ. "គឺរំលោភបំពានទៅលើសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ."[62]។

ខ. នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានឆ្លើយតបថា ប្រធានចៅក្រមមិនមានសិទ្ធិអំណាចបង្គាប់ណែនាំទៅផ្នែកគ្រប់គ្រងតុលាការឡើយ ដោយការកត់សម្គាល់ថា ផ្នែកគ្រប់គ្រងតុលាការបានទទួលសេចក្តីណែនាំផ្ទុយគ្នាពីក្រឡាបញ្ជីជាតិ និងក្រឡាបញ្ជីអន្តរជាតិនៃ អ.ប.ជ. រៀង១ខ្លួន ឱ្យបញ្ចូលរឿងក្តីទៅក្នុងបណ្ណាសារ និង ឱ្យជូនដំណឹងទៅ អ.ជ.ស.ដ. អំពីសេចក្តីពិចារណារបស់ អ.ប.ជ.[63]។

គ. នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានទទូចថា ចម្លើយរបស់ខ្លួន កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២០ គឺជា "ការបញ្ជាក់បំភ្លឺពីសិទ្ធិអំណាចជាផ្លូវការ" ដែលស្វែងរកដោយការិយាល័យរដ្ឋបាល ដោយថ្លែងថា "បើការិយាល័យរដ្ឋបាលនៅតែមានះនៅក្នុងអសកម្មភាពទៅទៀត ដោយគ្មានមូលដ្ឋានផ្លូវច្បាប់ នោះការរៀបចំសមាសភាពនៃ [ក.ស.ច.ស.] ឡើងវិញ គួរត្រូវលើកមកពិចារណា ដោយភាគីពាក់ព័ន្ធសម្រាប់ដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន ៦៩(២)(ក) នៃវិធានផ្ទៃក្នុង"[64]។ និង

ឃ. នៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ ប្រធាននៃ អ.ប.ជ. បានថ្លែងថា អ.ប.ជ. "បានបំពេញករណីកិច្ចរបស់ខ្លួនរួចរាល់ អនុលោមតាមច្បាប់ ហើយមិនតម្រូវឱ្យបំពេញកិច្ចរដ្ឋបាលណាមួយឡើយ" ដោយបញ្ជាក់ឡើងវិញអំពីគោលជំហររបស់ខ្លួននៅក្នុងអនុស្សរណៈថ្ងៃ ២៩ ខែមករា ឆ្នាំ ២០២០ ដែលថា មានតែសំអាងហេតុ និង ការចាត់ចែងរួមគ្នាទេ ទើបមាន

---

[62] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់ អ.ប.ជ ចំណងជើងថា "ការបញ្ជាក់បំភ្លឺអំពីសេចក្តីសម្រេចក្នុងរឿងក្តី ០០៤/២" ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ឯកសារ D359/34 ទំព័រ ២។

[63] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់ អ.ប.ជ ចំណងជើងថា "ការជូនដំណឹងអំពីសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២" ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ឯកសារ D359/35 ទំព័រ ៥។

[64] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់ អ.ប.ជ ចំណងជើងថា "ការផ្ទេរសំណុំរឿង ០០៤/២" ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ ឯកសារ D359/36 កថាខណ្ឌ ៣៧។

អានុភាពផ្លូវច្បាប់[65]។

១៦. *លោក មាស មុត ស្នើសុំការបញ្ជាក់បំភ្លឺ។* នៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ដោយសារតែការជាប់គាំងផ្នែកនីតិវិធីនៅក្នុងរឿងក្តី ០០៤/២ មេធាវីការពារក្តីបានស្នើសុំការបញ្ជាក់បំភ្លឺអំពីមូលដ្ឋានផ្លូវច្បាប់ ដែលចៅក្រមនៃ អ.ប.ជ. បានពិចារណាដាច់ពីគ្នាទៅលើអង្គសេចក្តីនៃដីកាដំណោះស្រាយខុសច្បាប់ ដែលបានជំទាស់មិនឱ្យបង្វិលសំណុំរឿងទៅ ស.ច.ស. ដោយមានការបង្គាប់ណែនាំឱ្យចេញដីកាដំណោះស្រាយមួយ ឬ ពិនិត្យសំណុំរឿងដោយខ្លួនឯង ហើយចេញដីកាដំណោះស្រាយផ្ទាល់ខ្លួន[66]។ ក្រៅពីការចោទសួរអំពីមូលដ្ឋានផ្លូវច្បាប់ពាក់ព័ន្ធនឹងថា តើ "គោលជំហរដើម" ដែលបម្រុងទុកសម្រាប់ការខ្វែងយោបល់គ្នារវាង ស.ច.ស. នៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់ពួកគាត់អាចអនុវត្តបានដោយរបៀបណា ដើម្បីដោះស្រាយចំពោះការចេញដីកាដំណោះស្រាយពីរដែលខុសច្បាប់នោះ[67] មេធាវីការពារក្តីបានស្នើសុំការបញ្ជាក់បំភ្លឺជាក់លាក់ទៅលើ[68]៖

ក. ថាតើ ស.ច.ស. បានគោរពតាមពាក្យពេចន៍ និង ស្មារតីនៃកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង និង យុត្តិសាស្ត្ររបស់ អ.ប.ជ. ឬទេ ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នាទាំងនេះ។

ខ. ថាតើ ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចមានសុពលភាពឬទេ ដោយសារតែដីកាទាំងពីរត្រូវចេញដោយរំលោភទៅនឹងវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

គ. ថាតើ អ.ប.ជ. បានពិចារណា ដោយយោងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ឬទេ ដើម្បីកំណត់ពីផលវិបាកនៃការប្រកាសថា ការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នាទាំងនេះ គឺ

---

[65] *រឿងក្តី អោ អាន* សំណុំរឿងលេខលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់ អ.ប.ជ ចំណងជើងថា "ការបញ្ជាក់សាជាថ្មីអំពីសេចក្តីសម្រេចលើសំណុំរឿង ០០៤/២" ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ ឯកសារ D359/37 ទំព័រ ២។

[66] សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ឯកសារ D267/24 ("សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ") កថាខណ្ឌ ១៥។

[67] *ដូចខាងលើ* កថាខណ្ឌ ៣៧។

[68] *ដូចខាងលើ* កថាខណ្ឌ ១៧, ១៩, ២១, ២៣, ២៥, ២៧, ២៨, ៣១, ៣៣, ៣៥, ៣៩។

ខុសច្បាប់។

ឃ. ថាតើ អ.ប.ជ. ខកខានមិនបានអនុវត្តអ្វីដែលខ្លួនពិចារណាថា ជាច្បាប់ដែលអាចអនុវត្តបាន ឬទេ ដោយការមិនបានបង្វិលដីកាដំណោះស្រាយទាំងនេះទៅ ស.ច.ស. ដោយមានការបង្គាប់ណែនាំ និង ដោយការមិនបានពិនិត្យសំណុំរឿងដោយខ្លួនឯងនោះ។

ង. ថាតើ ចៅក្រមនៃ អ.ប.ជ. ត្រូវបានតម្រូវឱ្យបំពេញកិច្ចរួមគ្នាជាសហសេវិកឬទេ នៅក្នុងការពិនិត្យសំណុំរឿងឡើងវិញ កាលបើពួកគេជ្រើសរើសមិនបង្វិលដីកាដំណោះស្រាយទៅ ស.ច.ស. វិញ។

ច. ថាតើ អ.ប.ជ. គួរបានធានាឱ្យកាន់តែប្រសើរនូវសច្ចភាពផ្លូវច្បាប់ និង តម្លាភាពឬទេ ដោយការបង្វិលសំណុំរឿងទៅ ស.ច.ស. ដោយមានការបង្គាប់ណែនាំ ឬ ក៏ដោយការពិនិត្យសំណុំរឿងឡើងវិញដោយខ្លួនឯងនោះ។

ឆ. ថាតើ អ.ប.ជ. មានកាតព្វកិច្ចត្រូវផ្តល់សេចក្តីសម្រេចជាឯកច្ឆន្ទទៅលើអានុភាពផ្លូវច្បាប់នៃការចេញដីកាដំណោះស្រាយខុសច្បាប់ទាំងនេះឬទេ ដើម្បីធានាដល់សច្ចភាពផ្លូវច្បាប់។

ជ. ថាតើមានសំអាងផ្លូវច្បាប់ ដែលចៅក្រមជាតិនៃ អ.ប.ជ. បានអនុវត្តឬទេ ដើម្បីសឱ្យឃើញថាត្រឹមត្រូវសម្រាប់ការពិនិត្យដីកាដំណោះស្រាយដែលខុសច្បាប់ទាំងនេះ។

ឈ. ថាតើ ចៅក្រមជាតិនៃ អ.ប.ជ. ពិចារណាដីកាសម្រេចលើកលែងចោទប្រកាន់ ជាមូលដ្ឋានត្រឹមត្រូវតាមច្បាប់ ដើម្បីរំលត់រឿងក្តីឬទេ នៅពេលដែល អ.ប.ជ. សម្រេចជាឯកច្ឆន្ទថា ស.ច.ស. បានរំលោភលើក្របខណ្ឌរបស់ អ.វ.ត.ក.។

ញ. ថាតើ ចៅក្រមជាតិនៃ អ.ប.ជ. បានងាកទៅប្រើគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*ឬទេ បន្ទាប់ពីអនុវត្តវិធានបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិលទៅលើវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ដើម្បីដោះស្រាយការចេញដីកាដំណោះស្រាយខុសច្បាប់ទាំងពីរនេះ។ និង

ដ. ថាតើ អ.ជ.ស.ដ. អាចត្រូវបានប្តឹងឱ្យទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខុសច្បាប់ ដោយមានវិការៈនីតិវិធី ស្របតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ឬទេ។

១៧. ***អ.ជ.ស.ដ. បដិសេធមិនទទួលពិនិត្យរឿងក្ដី ០០៤/២ ទេ។*** បន្ទាប់ពីមានសំណើរបស់ ស.ព.អ. សុំឱ្យ អ.ជ.ស.ដ. បន្តរឿងក្ដី ០០៤/២ ទៅជំនុំជម្រះ ចៅក្រមនៃ អ.ជ.ស.ដ. បានចេញសេចក្ដីប្រកាសព័ត៌មាននៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ដោយថ្លែងថា ពួកគាត់មិនអាចយល់ស្របគ្នាលើសំអាងហេតុរួមទេ។ ចៅក្រមជាតិនៃ អ.ជ.ស.ដ. បានយល់ឃើញថា អ.ជ.ស.ដ. មិនមានសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចណាមួយឡើយ ដោយសារតែអង្គជំនុំជម្រះមិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ អ.ប.ជ. និង ដោយសារតែរឿងក្ដីនេះត្រូវបានបិទនៅចំពោះមុខ អ.ប.ជ. តាមសេចក្ដីពិចារណារបស់ អ.ប.ជ.[69]។ ចៅក្រមអន្តរជាតិនៃ អ.ជ.ស.ដ. បានពិចារណាថា អ.ជ.ស.ដ. "មាន*សិទ្ធិអំណាចដែលជាប់ជាមួយ* ក្នុងការដោះស្រាយបញ្ហាបឋមៗ ដែលភាគីបានលើកឡើង..."។ ដោយសារតែ អ.ជ.ស.ដ. មិនអាចសម្រេចបានសំឡេងភាគច្រើនលើសលុប នោះ"ការចេញសេចក្ដីសម្រេចផ្លូវការមួយរបស់ អ.ជ.ស.ដ. មិនអាចធ្វើទៅបានឡើយ"[70]។

១៨. ***លោក មាស មុត ស្នើសុំដាក់សារណាបន្ថែមទៅលើបណ្ដឹងឧទ្ធរណ៍របស់គាត់។*** បន្ទាប់ពីមានសេចក្ដីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. មេធាវីការពារក្ដីបានស្នើសុំដាក់សារណាបន្ថែមទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ដោយសារតែសេចក្ដីថ្លែងការណ៍របស់ អ.ជ.ស.ដ. បានលើកឡើងពីលទ្ធភាពនៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនអាចជំទាស់បាន តាមលងបន្លាចលោក មាស មុត ជារៀងរហូត[71]។ មេធាវីការពារក្ដីបានស្នើសុំឱ្យ អ.ប.ជ. ដោយគោរពតាមប្រណិធាន និង ទំនួលខុសត្រូវរបស់ខ្លួន ក្នុងការធានាភាពត្រឹមត្រូវនៃដំណើរការនីតិវិធី ចាំបាច់ត្រូវតែផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ វៀរលែងតែ អ.ប.ជ. ព្រមព្រៀងគ្នាលើវិវឌ្ឍនាការនៃរឿងក្ដី ០០៣[72]។

១៩. ***ស.ព.អ. ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. ក្នុងរឿងក្ដី ០០៤/២។***

---

[69] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក។៖ *សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក. ស្ដីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន* ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ គេហទំព័រ https://eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao ("សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី ០០៤/២")។

[70] *ដូចខាងលើ*។

[71] សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 ("សារណាបន្ថែមរបស់ មាស មុត") កថាខណ្ឌ ២៤។

[72] *ដូចខាងលើ* កថាខណ្ឌ ៤៤-៥២។

ដោយការអះអាងពីអសកម្មភាពរបស់ អ.ជ.ស.ដ. និង សេចក្ដីប្រកាសព័ត៌មានចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ២០២០ បានបង្កើតជា "សេចក្ដីសម្រេច"មួយ ដែលបញ្ចប់រឿងក្ដីនេះយ៉ាងមានប្រសិទ្ធភាព ស.ព. អ. បានប្ដឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២០[73]។ ស.ព.អ. បានលើកទឡ្ហីករណ៍ថា អ.ជ.ស.ដ. ខកខានមិនបានផ្ដល់អានុភាពទៅលើ "គោលជំហរដើម" ខកខានមិនបានសំអាងលើសិទ្ធិអំណាចដែលជាប់ជាមួយរបស់ខ្លួន ក្នុងការប្រកាសពីបញ្ហានៃភាពត្រឹមត្រូវតាមច្បាប់ បានដាក់លក្ខខណ្ឌតម្រូវរដ្ឋបាលបន្ថែមដោយចិត្តឯង ទៅលើការជូនដំណឹងជាផ្លូវការអំពីសេចក្ដីពិចារណារបស់ អ.ប.ជ. និង បានរំលត់រឿងក្ដីនេះយ៉ាងមានប្រសិទ្ធភាព ដោយផ្អែកលើមូលដ្ឋានដែលមិនត្រូវបានអនុញ្ញាតឱ្យ[74]។

២០. ***លោក មាស មុត ស្នើសុំអន្តរាគមន៍នៅក្នុងរឿងក្ដី ០០៤/២។*** ដោយសារតែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿក្ដីង ០០៤/២ អាចនឹងប៉ះពាល់ជាទូទៅដល់ដំណើរការនីតិវិធីនៅក្នុងរឿងក្ដី ០០៣ មេធាវីការពារក្ដីបានស្នើសុំធ្វើអន្តរាគមន៍នៅក្នុងរឿងក្ដី ០០៤/២ ដើម្បីបង្ហាញពី៖[75]

ក. ហេតុដែល អ.ជ.ស.ដ. មិនបានទទួលពិនិត្យសំណុំរឿងនេះ ដោយសារតែមិនមានដីកាដំណោះស្រាយដែលមានសុពល។

ខ. ហេតុដែល សេចក្ដីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ អសកម្មភាព និង ការបញ្ជូនត្រឡប់វិញនូវសារណាសុំពិចារណារបស់ ស.ព.អ. ពុំមែនជាសេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់ដំណើរការនីតិវិធី "ដែលអាចប្ដឹងសាទុក្ខបាន"ទេ។

គ. ហេតុដែល អ.ប.ជ. កំពុងមានសំណុំរឿង ០០៤/២ នៅក្នុងដៃ ហេតុដូច្នេះហើយ ទើបអង្គជំនុំជម្រះ ពុំចាំបាច់អនុវត្តអំណាចដែលជាប់ជាមួយរបស់ខ្លួននោះទេ។

---

[73] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក បណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1 កថាខណ្ឌ ៤២។

[74] *ដូចខាងលើ* កថាខណ្ឌ ៤៣។

[75] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/2 ("សំណើសុំធ្វើអន្តរាគមន៍របស់ មាស មុត") កថាខណ្ឌ ១១-១២។

ឃ. ហេតុដែល គោលជំហរ "ដើម" នៅក្នុងកិច្ចព្រមព្រៀង និង ក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ដែលចែងថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" កាលណាសហព្រះរាជអាជ្ញា ឬ ស.ច.ស. ខ្វែងយោបល់គ្នា *អនុវត្តបានតែនៅក្នុងដំណាក់កាលស៊ើបអង្កេតប៉ុណ្ណោះ*។

ង. ហេតុដែល ទោះបីជាវិធាន ៧៧(១៣)(ខ) ត្រូវបានចាត់ទុកថាជា*ច្បាប់ពិសេស* ធៀបទៅនឹងវិធាន ៧៧(១៣)(ក) ក្ដី ក៏វិធានទាំងពីរត្រូវបានរៀបចំឡើង សម្រាប់ការចេញដីកាដំណោះស្រាយតែមួយ ហើយ អ.ប.ជ. បានសម្រេចជាឯកច្ឆន្ទថា ដីកាដំណោះស្រាយទាំងពីរត្រូវបានចេញដោយខុសច្បាប់។

ច. ហេតុដែល វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ក៏ត្រូវបានរៀបចំឡើងសម្រាប់ដីកាដំណោះស្រាយតែមួយ ហើយមិនមានន័យថា អ.ជ.ស.ដ. អាចត្រូវបានប្ដឹងឱ្យទទួលពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចេញដោយខុសច្បាប់នោះទេ។ និង

ឆ. ហេតុដែល ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង និង អ្នកព្រាងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. មិនយល់ស្របគ្នាក្នុងការបញ្ជូនរឿងក្ដីទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នានោះទេ។

២១. អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសំណើសុំធ្វើអន្តរាគមន៍របស់មេធាវីការពារក្ដី នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០[76]។

២២. ***អង្គជំនុំជម្រះតុលាការកំពូល បញ្ចប់សំណុំរឿង ០០៤/២។*** នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់សំណុំរឿង ០០៤/២[77] ដោយសម្រេចថា នៅពេលដែល អ.ប.ជ. បានប្រកាសជាឯកច្ឆន្ទថា ស.ច.ស. បានបំពេញកិច្ចដោយខុសច្បាប់ នោះដីកាដំណោះស្រាយទាំងនេះត្រូវចាត់ទុកជាមោឃៈ ហើយវាលែងពាក់ព័ន្ធដែលថា អ.ប.ជ. មិនអាចទទួលបាន

[76] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអានុភាពដែលនាំឱ្យបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០ ឯកសារ E004/2/2/1។

[77] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០៤/២ ។

សំឡេងភាគច្រើនលើសលុបលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ភាគីនោះទេ[78]។ *"កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬ លទ្ធផលត្រឹមត្រូវតាមច្បាប់ទេ។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់ទេ"*[79]។ ទោះបីជាមានការយល់ឃើញថា គោលដៅនៃយន្តការដោះស្រាយជម្លោះ គឺត្រូវ"ទប់ស្កាត់ភាពទាល់ច្រក មិនឱ្យរាំងដំណើរការនីតិវិធីបន្តដំណើរទៅរកការជំនុំជម្រះ"ក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដោយ"ឥតច្រឡំ"ថា "រឿងក្តីមួយពុំអាចឈានទៅជំនុំជម្រះឡើយ កាលណាគ្មានដីកាដំណោះស្រាយសុពល"[80]។

២៣. ការកត់សម្គាល់ថា ការយល់ឃើញរបស់ អ.ប.ជ. ដែលថា វិធាន ៧៩(១) ណែនាំថា អ.ប.ជ. "មានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬ កែប្រែដីកាដំណោះស្រាយ" និងថា "ការបំពេញតួនាទីសភាស៊ើបសួរកម្ពុជានៅ អ.វ.ត.ក." អ.ប.ជ. ត្រូវស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង នៅពេលទទួលពិនិត្យដីកាសម្រេចលើកលែងចោទប្រកាន់ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា ការយល់ឃើញទាំងអស់នេះ "នឹងនាំឱ្យអ្នកវិភាគសមហេតុផល អាចសន្និដ្ឋានបានថា [អ.ប.ជ.] បានដឹងអំពីសិទ្ធិអំណាចរបស់ខ្លួន ក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និង ចេញដីកាដំណោះស្រាយសុពលភាពរបស់ខ្លួនផ្ទាល់"[81]។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អ.ប.ជ. "គប្បីចាប់យកមួយជំហានបន្ថែមទៀត និង ផ្តល់នូវការសម្រេចស្ថាពរពិតជាក់ស្តែង"[82]។

២៤. ការពិចារណាថា ការខ្វែងយោបល់គ្នារបស់ ស.ច.ស. "បានសម្រេចយ៉ាងតឹងតែង" ដែលមិនអាចសម្របសម្រួល បាននាំឱ្យពួកគាត់ចុះកំណត់ហេតុការខ្វែងយោបល់គ្នា និង ដោយជៀសពុំរួចពីការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា[83] ដែលថា ស.ព.អ. បានកំពុងធ្វើចំណាត់ការដោយ

---

[78] *ដូចខាងលើ* កថាខណ្ឌ ៥៣។

[79] *ដូចខាងលើ* កថាខណ្ឌ ៦៧។

[80] *ដូចខាងលើ* កថាខណ្ឌ ៦៨។

[81] *ដូចខាងលើ* កថាខណ្ឌ ៦១ ដែលដកស្រង់ *ក្នុងចំណោមនោះ* សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៣០។

[82] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។

[83] *ដូចខាងលើ* កថាខណ្ឌ ៦២។

គ្មានការគាំទ្រ (ឬ ជំទាស់) ពី ស.ព.ជ.[84] និងថា "ពុំមានការស្រុះស្រួលគ្នា បន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរដែល អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ" អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ក្នុងករណីមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន នោះរឿងក្ដី ០០៤/២ គប្បីត្រូវបញ្ចប់[85]។

២៥. ***អ.ប.ជ. បដិសេធសំណើរបស់លោក មាស មុត សុំការបញ្ជាក់បំភ្លឺ។*** នៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ អ.ប.ជ. បានបដិសេធសំណើរបស់លោក មាស មុត សុំការបញ្ជាក់បំភ្លឺ ដោយពិចារណាថា ការចេញសេចក្ដីពិចារណា ឬ សេចក្ដីសម្រេចរបស់ អ.ប.ជ. នៅក្នុងដំណើរការនីតិវិធីផ្សេងគ្នា "មិនមានអានុភាពដោយផ្ទាល់ទៅលើរឿងក្ដីដែលមិនទាន់សម្រេចឡើយ" បើទោះបីជាបានថ្លែងថា អ.ប.ជ. "មិនមែនមិនដឹងអំពីទស្សនករណ៍ដែលថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ អាចត្រូវបានយល់ច្រឡំនោះ"[86]។ ទោះបីជាមានអនុស្សរណៈផ្ទុយគ្នា ដែលកើតចេញពី អ.ប.ជ. ពាក់ព័ន្ធអានុភាពផ្លូវច្បាប់នៃសេចក្ដីពិចារណាក្នុងរឿងក្ដី ០០៤/២ របស់ខ្លួនក្ដី ក៏ អ.ប.ជ. បានយល់ឃើញថា "សេចក្ដីពិចារណានេះបានផ្ដល់សច្ចភាពផ្លូវច្បាប់ និង តម្លាភាព ដែលបានតម្រូវសម្រាប់សេចក្ដីសម្រេចរបស់តុលាការ ដែលកើតចេញពីអង្គជំនុំជម្រះ តាមកាលៈទេសៈជាក់លាក់នៃសំណុំរឿងនោះ"[87]។

២៦. ***អ.ប.ជ. បដិសេធសារណាបន្ថែមរបស់លោក មាស មុត។*** អ.ប.ជ. បានបដិសេធសារណាបន្ថែមរបស់លោក មាស មុត នៅថ្ងៃតែមួយ ដែលអង្គជំនុំជម្រះបដិសេធសំណើសុំបញ្ជាក់បំភ្លឺរបស់គាត់ ដោយយល់ឃើញថា សេចក្ដីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. នៅក្នុងរឿងក្ដីមួយផ្សេង "មិនមានអានុភាពភ្លាមៗ ឬ ដោយផ្ទាល់លើរឿងក្ដីដែលមិនទាន់សម្រេចនោះឡើយ"[88] ថាបណ្ដឹងឧទ្ធរណ៍

---

[84] *ដូចខាងលើ* កថាខណ្ឌ ៦៥។

[85] *ដូចខាងលើ* កថាខណ្ឌ ៦៩។

[86] សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/២ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ឯកសារ D266/24 & D267/32 កថាខណ្ឌ ២៨។

[87] *ដូចខាងលើ* កថាខណ្ឌ ៣១។

[88] សេចក្ដីសម្រេចលើសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់គាត់ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ឯកសារ D267/33 កថាខណ្ឌ ៣២។

នានាត្រូវបានពន្យល់យ៉ាងលម្អិតនិងបានជជែកដេញដោលដោយផ្ទាល់មាត់[89] ហើយថាកាលៈទេសៈនេះមិនបានតម្រូវឱ្យមានការពឹងផ្អែកលើសិទ្ធិអំណាចដែលជាប់ជាមួយរបស់ខ្លួនឡើយ (ថ្វីបើអង្គជំនុំជម្រះបានអះអាងបញ្ជាក់ឡើងវិញថា អង្គជំនុំជម្រះមានសិទ្ធិអំណាចដែលជាប់ជាមួយ ដើម្បីការពារដំណើរការគ្រប់គ្រងយុត្តិធម៌ឱ្យល្អ និង ត្រឹមត្រូវ)[90]។

២៧. ***អ.ប.ជ. ចេញសេចក្តីពិចារណារបស់ខ្លួននៅក្នុងរឿងក្តី ០០៣។*** នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ អស់រយៈពេល ១៦ ខែ បន្ទាប់ពីទឡ្ហីករណ៍ផ្ទាល់មាត់ អ.ប.ជ. បានចេញសេចក្តីពិចារណារបស់ខ្លួននៅក្នុងរឿងក្តី ០០៣ ដោយប្រើប្រាស់ និង បញ្ចូលសំអាងហេតុជាច្រើនរបស់ខ្លួនពីសេចក្តីពិចារណានៅក្នុងរឿងក្តី ០០៤/២[91]។ "ការស្តីបន្ទោសជាថ្មីម្តងទៀត ទៅលើស្ថានការណ៍ដ៏អាក្រក់ផ្នែកច្បាប់ដែលសកម្មភាពខុសច្បាប់របស់ [ស.ច.ស.] បានបង្កើតឡើងចំពោះដំណើរការនីតិវិធីផ្សេងទៀតរបស់ អ.វ.ត.ក."[92] អ.ប.ជ. ប្រកាសយ៉ាងជូរចត់ (ដូចក្នុងរឿងក្តី ០០៤/២) ថា ស.ច.ស. បានបង្ខូរដោយចេតនា និង ដោយគិតគូរច្បាស់លាស់នូវដំណើរការយុត្តិធម៌ ដោយសារតែ "ពួកគាត់ប្រហែលជាមានចេតនាធ្វើឱ្យបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិអំណាចរបស់ [អ.ប.ជ.]"[93] ដោយស្រុះស្រួលគ្នាក្នុងការចេញក្នុងពេលជាមួយគ្នា នូវដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា។

២៨. អ.ប.ជ. បានយល់ឃើញថា "កំហុសឆ្គងរបស់ ស.ច.ស. បានបង្កអន្តរាយដល់ប្រព័ន្ធទាំងមូលដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ" ហើយថា មិនគ្រាន់តែជាការរំលោភបំពានទៅលើក្របខណ្ឌរបស់ អ.វ.ត.ក. ប៉ុណ្ណោះទេ "*ការអនុវត្តដោយខុសឆ្គង* [របស់ ស.ច.ស.] អាចមានតម្លៃស្មើនឹងការបដិសេធភាពយុត្តិធម៌" ដោយសារតែ អ.ប.ជ. "មិនអាចបដិសេធថា ពួកគាត់ប្រហែលបានប៉ុនប៉ងធ្វើឱ្យបរាជ័យគោលជំហរដើម និង ក្នុងការធ្វើឱ្យរសាយ

[89] *ដូចខាងលើ* កថាខណ្ឌ ៣៣។

[90] *ដូចខាងលើ* កថាខណ្ឌ ៣៥។

[91] *ប្រៀបធៀប* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 & D267/35 ("សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៣") កថាខណ្ឌ ៧៨-១០៩ ជាមួយសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៩១-១២៤។

[92] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៩។

[93] *ដូចខាងលើ* កថាខណ្ឌ ១០៨។

ដល់សិទ្ធិអំណាចរបស់ អ.ប.ជ.”[94]។

២៩. ការបកស្រាយវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ថាមានចែងច្បាស់លាស់អំពីដីកាដំណោះស្រាយតែមួយ ដែល *ឬមួយ* ត្រូវចោទប្រកាន់ជនត្រូវចោទបញ្ជូនទៅជំនុំជម្រះ *ឬក៏* ត្រូវរំលត់រឿងក្តីនោះ[95] អ.ប.ជ. បានយល់ឃើញថា ស.ច.ស. “បានប្រព្រឹត្តកំហុសដ៏ធំធេងលើអង្គច្បាប់ នៅក្នុងរឿងក្តីនេះ ដោយការយល់ឃើញថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក. អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា”[96] “[បាន]ធ្វើឱ្យអន្តរាយដល់មូលដ្ឋានគ្រឹះនៃប្រព័ន្ធចម្រុះ និង ដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក.”[97] “បានដឹងពីការលំបាក ដែលចំណាត់ការរបស់ពួកគេអាចបង្កឱ្យមានឡើង មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍ និងមុនដំណាក់កាលជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងរឿងក្តី ០០៣ ទៅទៀត”[98] ហើយថែមទាំងបានរារាំងដោយឥតខ្វល់ខ្វាយនឹងអនុវត្តភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការសម្រេចសេចក្តីលើបញ្ហា ដែលបានប្តឹងមកឱ្យពួកគាត់ទទួលពិនិត្យ[99]។

៣០. អ.ប.ជ. ក៏បានយល់ឃើញផងដែរថា វាជា“រឿងប្លែកៗ ដែលដីកាដំណោះស្រាយផ្ទុយគ្នា ត្រូវបានចេញក្នុងថ្ងៃតែមួយ ជាភាសាតែមួយ ដោយមានការប្រកាសរួមគ្នា ដោយ [ស.ច.ស.] ទាំងពីរនាក់ថា ពួកគាត់បានយល់ស្របគ្នាលើការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា”[100] និងថា ស.ច.ស. បានផ្តល់ “សំអាងហេតុតិចតួចគួរឱ្យកត់សម្គាល់ ដោយលើកឡើងតែត្រឹមសេចក្តីសម្រេចកន្លងមករបស់ពួកគាត់ត្រឹមតែពីរប៉ុណ្ណោះ”[101]។ បន្តតាមផ្លូវដែល អ.ប.ជ. យល់ថា “មិនត្រឹមតែជាឧទាហរណ៍ដាច់តែឯងប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរបស់ពួកគាត់ [ស.ច.ស.] នៅក្នុងករណីនេះ គាំទ្រទម្រង់មួយដែល [ស.ច.ស.] បានអនុម័តយកដោយច្បាស់លាស់ ក្នុងការដោះ

---

[94] *ដូចខាងលើ* កថាខណ្ឌ ១០៨។

[95] *ដូចខាងលើ* កថាខណ្ឌ ១០៣។

[96] *ដូចខាងលើ* កថាខណ្ឌ ៨៨។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៥ ដែល អ.ប.ជ. បានអះអាងថា ស.ច.ស. បានប្រព្រឹត្ត “កំហុសអង្គច្បាប់ធ្ងន់ធ្ងរ ដែលជាមូលដ្ឋាននៃសំអាងហេតុរបស់ពួកគេ”។

[97] សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៦។

[98] *ដូចខាងលើ* កថាខណ្ឌ ១០៧។

[99] *ដូចខាងលើ* កថាខណ្ឌ ១០៥។

[100] *ដូចខាងលើ* កថាខណ្ឌ ១០៧។

[101] *ដូចខាងលើ* កថាខណ្ឌ ១០៦។

ស្រាយបណ្តារឿងក្តីចុងក្រោយទាំងអស់ នៅក្នុងបញ្ជីសំណុំរឿងរបស់ អ.វ.ត.ក.”[102] “មិនដែលធ្លាប់មានសំណុំរឿងព្រហ្មទណ្ឌណា នៅក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អន្តរជាតិ និង ប្រព័ន្ធច្បាប់ជាតិដទៃទៀត ដែលបញ្ចប់ដោយការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរ ក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យចៅក្រមតែមួយនោះទេ”[103]។

៣១. ទោះបីជាបានអះអាងបញ្ជាក់ពីសិទ្ធិអំណាចរបស់ខ្លួនក្នុងការស៊ើបអង្កេត និង ចេញដីកាដំណោះស្រាយដែលកែប្រែក៏ដោយ ក៏ អ.ប.ជ. បានបដិសេធមិនអនុវត្ត តាមការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី ០០៤/២ នោះទេ។ ដូចដែលពួកគាត់បានធ្វើនៅក្នុងរឿងក្តី ០០៤/២ ចៅក្រមនៃ អ.ប.ជ. បានបំបែកទៅជាភាគីជាតិ និង ភាគីអន្តរជាតិរៀងៗខ្លួន ដើម្បីផ្តល់ការគាំទ្រដល់ដីកាដំណោះស្រាយ តាមការជ្រើសរើសរបស់ពួកគាត់[104]។

៣២. ទោះបីជាប្រើប្រាស់ស្ទៀតផ្សេង ក្រៅពីយោបល់ដាច់ពីគ្នារបស់ពួកគាត់នៅក្នុងរឿងក្តី ០០៤/២ ក្តី ក៏ចៅក្រមជាតិនៃ អ.ប.ជ. បានយល់ឃើញស្រដៀងគ្នាផងដែរថា សំណុំរឿង ០០៣ “គប្បីតម្កល់ទុកទៅក្នុងបណ្ណសារនៃ អ.វ.ត.ក.”[105]។ ពួកគាត់បានផ្តល់សំអាងហេតុថា អ.ប.ជ. មិនអាចអនុវត្តយន្តការដោះស្រាយជម្លោះដូចនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងបានទេ ដោយសារតែ ស.ច.ស. បានស្រុះស្រួលគ្នាមិនបញ្ជូនការខ្វែងយោបល់គ្នារបស់ខ្លួនទៅ អ.ប.ជ. “ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា”[106] ដោយផ្អែកតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ស.ច.ស. មានឋានៈដូចគ្នា ហើយបើយោងតាមគោលការណ៍សច្ចធារណ៍នៃនិរទោស “ច្បាប់ពុំអនុញ្ញាតឱ្យ អ.ប.ជ. សម្រេចថា កិច្ចរបស់ [ស.ច.ស.] ណាម្នាក់ មានឧត្តមភាពនោះទេ”[107] ហើយ “ហេតុដូច្នេះ ដីកាដំណោះស្រាយទាំងពីររក្សាបាននូវតម្លៃស្មើគ្នាដដែល”[108]។

---

[102] *ដូចខាងលើ* កថាខណ្ឌ ១០៨។

[103] *ដូចខាងលើ* កថាខណ្ឌ ១០៩។

[104] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១១-១១៨, ១១៩-៣៥៨។

[105] *ដូចខាងលើ* កថាខណ្ឌ ១១៨។

[106] មានភាពខុសគ្នាក្នុងការបកប្រែកថាខណ្ឌ ១១៥។ គួរបកប្រែ “ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា និង សុពលភាពដូចគ្នា” (ការបកប្រែក្រៅផ្លូវការ)។

[107] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៣-១១៦។

[108] *ដូចខាងលើ* កថាខណ្ឌ ១១៧។

៣៣. ប្រហែលគ្នានឹងគោលជំហររបស់ពួកគេនៅក្នុងរឿងក្តី ០០៤/២ ដែរ បើទោះបីជាបានដឹងការបញ្ជាក់អះអាងអំពីចេតនាអាក្រក់ និង កំហុសឆ្គងដែលមិនសមស្របក្តី បើទោះបីជាបានថ្កោលទោសចំពោះការព្រមព្រៀងគ្នារបស់ ស.ច.ស.អ. ក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ ក្នុងពេលជាមួយគ្នា នឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សមភាគីជាតិរបស់គាត់ក្តី និង បើទោះបីជាបានប្រកាសថា ការចេញដីកាដំណោះស្រាយពីទាំងពីរគឺខុសច្បាប់ក្តី ក៏ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានប្រកាសថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ. មានសុពលភាព ហើយដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ. *ហួសពីសមត្ថកិច្ច*[109]។ ទោះបីជាមានពាក្យពេចន៍បែបអន្ទានុសិទ្ធិ នៅក្នុងវិធាន ៧២(២) នៃវិធានផ្ទៃក្នុងក្តី ក៏ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានផ្តល់សំអាងហេតុថា ស.ច.ស. ត្រូវតម្រូវឱ្យទៅរកយន្តការដោះស្រាយជម្លោះ មុនពេលចេញដីកាដំណោះស្រាយ[110] ដោយបានប្រកាសថា "គោលការណ៍នៃការបន្តការស៊ើបអង្កេតតាមផ្លូវតុលាការនេះ គ្រប់គ្រងលើបញ្ហាដែលនៅចំពោះមុខនេះ"[111]។

៣៤. ក្នុងការសម្រេចពីសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ទោះជាយល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពក្តី ក៏បានយល់ឃើញថា ស.ច.ស.អ.៖

ក. តាមតែអំពើចិត្ត បានប្រតិបត្តិតាមការជូនដំណឹងពីការបិទការស៊ើបសួរតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង ដោយដកហូតពីភាគីនានានូវរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[112]។

ខ. មិនយកចិត្តទុកដាក់ក្នុងការប្រស្រ័យទាក់ទងសំណុំរឿង និង បានបង្កើតឱ្យមានការពន្យារពេលហួសហេតុ ដោយការរង់ចាំរយៈពេលពីរខែ បន្ទាប់ពីចេញសេចក្តីជូនដំណឹងលើកទីពីរតាមវិធាន ៦៦(១) ទើបបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា[113]។

---

[109] *ដូចខាងលើ* កថាខណ្ឌ ២៥៩។

[110] *ដូចខាងលើ* កថាខណ្ឌ ២៥៦-២៥៨។

[111] *ដូចខាងលើ* កថាខណ្ឌ ២៥៦។

[112] *ដូចខាងលើ* កថាខណ្ឌ ១៣៩-១៤១។

[113] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤២-១៤៣។

គ. ខកខានមិនបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួននៅក្នុងរយៈពេលសមស្រប[114]។

ឃ. ដោយភាន់ច្រឡំ "[បាន]តម្កល់គោលការណ៍កំណត់ប្រភេទនៃភស្តុតាងតាមឋានានុក្រម និងតាមទម្រង់ច្បាប់ ដោយផ្អែកលើប្រភពជាជាងលើខ្លឹមសារ"[115]។ និង

ង. ខកខានមិនបានបង្គាប់ឱ្យឃុំខ្លួនលោក មាស មុត មុនពេលជំនុំជម្រះ[116]។

៣៥. ពាក់ព័ន្ធនឹង ស.ច.ស.ជ. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានយល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ "ជាការព្យាយាមមួយ ដើម្បីគេចចេញពីនីតិវិធីដែលតម្រូវចាំបាច់ សម្រាប់ការខ្វែងយោបល់គ្នា" គឺ "ជាការព្យាយាមដោយឥតអៀនខ្មាស់ក្នុងការគេចវេសទាំងស្រុង ពីលក្ខខណ្ឌតម្រូវជាចាំបាច់និងសំខាន់នេះ ដែលធ្វើឱ្យខូចខាតដល់អត្ថបទគតិយុត្តិ ដែលជាមូលដ្ឋានរបស់ អ.វ. ត.ក." និង គឺ"*ហួសពីសមត្ថកិច្ច* ដូច្នេះហើយ ត្រូវចាត់ទុកជាមោឃៈ ដោយសារបង្កជាការព្យាយាមមួយធ្វើឱ្យខូចខាតដល់គោលជំហរដើម ដែលមានចែងក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[117]។

៣៦. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ក៏បានបញ្ជាក់បង្ហាញពីការខ្វែងយោបល់គ្នាជាមួយអង្គជំនុំជម្រះតុលាការកំពូលដែរ ទោះបីបដិសេធមិនពន្យល់ពីហេតុដែល អ.ប.ជ. មិនបានអនុវត្តតាមឧបាស្រ័យដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ ដោយផ្អែកលើសេចក្តីប្រកាសផ្ទាល់របស់ អ.ប.ជ. ដោយការយល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូល ៖

ក. បានបង្កើត "ជំហានលោតផ្លោះមួយដល់សំអាងហេតុ" ដោយ "ហាក់ដូចជានិយាយពាំត្រណោតចំពោះការសម្រេចរបស់ [អ.ប.ជ.] ដែលថាកម្រងសកម្មភាពរបស់ [ស.ច.ស.] ក្នុងការចេញដីកាដំណោះស្រាយគឺខុសច្បាប់ ដោយមានការសន្និដ្ឋានថា ដីកាដំណោះស្រាយគឺ "មោឃៈ"អញ្ចឹងឯង"[118]។

ខ. បានធ្វើ"សន្និដ្ឋានសរុប ដោយគ្មានការបង្ហាញដោយសមហេតុផល" ពីហេតុដែលអនីត្យានុកូលភាពផ្នែកនីតិវិធីនៃកិច្ចរបស់ ស.ច.ស. ក្នុងការបង្កើតដីកាដំណោះស្រាយ "នឹងបណ្តាលឱ្យ

---

[114] *ដូចខាងលើ* កថាខណ្ឌ ១៣០។

[115] *ដូចខាងលើ* កថាខណ្ឌ ១៥៦។

[116] *ដូចខាងលើ* កថាខណ្ឌ ៣៤៥-៣៥៨។

[117] *ដូចខាងលើ* កថាខណ្ឌ ២៦០, ២៦២។

[118] *ដូចខាងលើ* កថាខណ្ឌ ២៧៣។

មានការខូចខាតទាំងស្រុងទៅលើដីកាដំណោះស្រាយទាំងពីរ ដែលមានបញ្ហា" ពីព្រោះកំហុសនីតិវិធី ត្រូវតែបណ្ដាលឱ្យមាន "លទ្ធផលមិនយុត្តិធម៌ទាំងស្រុងក្នុងដំណើរការនីតិវិធីរបស់តុលាការ" ទើបនាំទៅរកការកែប្រែសាលក្រមនោះ[119]។

គ. "បានតាក់តែងឡើងយ៉ាងប៉ិនប្រសប់ ដើម្បីជាលេសដ៏ល្អ ក្នុងការនាំយកដំណើរការនីតិវិធីឈានទៅដល់ការបញ្ចប់"នូវ"បុរេលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលអំពីការជូនដំណឹង និង ការបញ្ជូនដែលរងការចោទប្រកាន់"[120]។

ឃ. បានយល់ឃើញថា វាមិនចាំបាច់ទេ "ក្នុងការវិភាគលើអត្ថបទនៃសេចក្ដីសម្រេចជាក់ស្ដែងរបស់ [អ.ប.ជ.] ដើម្បីបញ្ជាក់បំភ្លឺ ... ថាតើ អ.ប.ជ. បានយល់ឃើញជាឯកច្ឆន្ទដែរឬទេថា ដីកាដំណោះស្រាយទាំងពីរ គឺមោឃៈ និង ឥតបានការនោះឬទេ"[121]។

ង. បានបញ្ចប់តាមអំពើចិត្តនូវរឿងក្ដី ០០៤/២ ដោយពុំមានដីកាដំណោះស្រាយ ដែល "មិននាំឱ្យមានសច្ចភាព តម្លាភាព ឬ អវសានភាពផ្លូវច្បាប់ឡើយ"[122]។

ច. បានធ្វើសេចក្ដីសម្រេចរបស់ខ្លួន ដោយមិនពិនិត្យភស្ដុតាងឡើងវិញ "តាមរយៈតែសេចក្ដីណែនាំបញ្ចប់ ដែលមានលក្ខណៈជាអនុក្រឹត្យទៅវិញ"[123]។

ឆ. បានបកស្រាយខុសលើសេចក្ដីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ. លើដំណើរត្រូវរ៉ូវគ្នាដោយខុសច្បាប់រវាង ស.ច.ស. "ក្នុងការគេចចេញពីនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា" ដោយខកខានមិនបានយល់ដឹងថា ការស៊ើបអង្កេតត្រូវបន្ត[124]។ និង

ជ. "បានពោលបញ្ឆិតបញ្ឆៀងថា ការបញ្ចប់ដំណើការនីតិវិធីគឺគឺសមស្របហើយ ដោយពិចារណាលើការស៊ើបអង្កេតដែលមានរយៈពេលដប់បីឆ្នាំ ... [ដែល] មិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានផ្លូវច្បាប់ដែលសុពលឡើយ ដោយសារតែក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ពុំចែងអំពី

[119] *ដូចខាងលើ* ជើងទំព័រ ៦០៩។

[120] *ដូចខាងលើ* ជើងទំព័រ ៥៩៤។

[121] *ដូចខាងលើ* កថាខណ្ឌ ២៧៤។

[122] *ដូចខាងលើ* កថាខណ្ឌ ២៧៩។

[123] *ដូចខាងលើ* កថាខណ្ឌ ២៨០។

[124] *ដូចខាងលើ* កថាខណ្ឌ ២៧៥។

ពេលវេលាកំណត់ជាក់លាក់ ដែលអង្គជំនុំជម្រះតុលាការកំពូល អាចបញ្ចប់រឿងក្តីណាមួយ តាមរយៈដីកាសម្រេចបែបប្រតិបត្តិនោះ”[125]។

៣៧. ***អ.ជ.ស.ដ. ជូនដំណឹងថា ខ្លួនមិនបានទទួលរឿងក្តី ០០៣ មកពិនិត្យទេ។*** បន្ទាប់ពីមានសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ស.ព.អ. បានដាក់បញ្ជីឈ្មោះសាក្សីរបស់គាត់។ ក្រឡាបញ្ជីនៃ អ.ជ.ស.ដ. បានរំលឹកថា “[អ.ជ.ស.ដ.] មិនត្រូវបានជូនដំណឹងអំពី “សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនោះឡើយ” ហើយក៏មិនបានទទួលសំណុំរឿងនេះដែរ។ ដូច្នេះហើយ ទើប [អ.ជ.ស.ដ.] មិនទទួលយកសារទាក់ទងណាមួយពីភាគី (សូមមើលផងដែរ វិធាន ៧៧/១៤ នៃវិធានផ្ទៃក្នុង)”[126]។

៣៨. ***ស.ព.អ. ស្នើឱ្យ ស.ច.ស. បញ្ជូនសំណុំរឿង០០៣ ទៅ អ.ជ.ស.ដ.។*** នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ស.ព.អ. បានស្នើឱ្យ ស.ច.ស. ចាត់រាល់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីបង្គាប់ឱ្យអង្គភាពគ្រប់គ្រងតុលាការបញ្ជូនរឿងក្តី ០០៣ ទៅ អ.ជ.ស.ដ.[127]។ មេធាវីការពារក្តីបានតបថា សំណើរបស់ ស.ព.អ. មិនអាចទទួលយកបានទេ ព្រោះដីកាដំណោះស្រាយទាំងពីរត្រូវបានចាត់ទុកជាមោឃៈ និង ឥតបានការ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. មិនបានផ្តល់សំអាងហេតុ ឬ សំអាងផ្លូវច្បាប់សមស្រប នៅក្នុងការងាកចេញពីការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូល អ.ប.ជ. នៅតែមានរឿងក្តីនេះនៅក្នុងដៃ ហើយ អ.ប.ជ. មិនបានសម្រេចដោយសំឡេងភាគច្រើនលើសលុបថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពនោះទេ[128]។

៣៩. ***ស.ច.ស. បដិសេធសំណើរបស់ ស.ព.អ. សុំឱ្យបញ្ជូនសំណុំរឿង។*** នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២១ ស.ច.ស. បានច្រានសំណើរបស់ ស.ព.អ. ចោល ព្រោះថាមិនមានមូលដ្ឋានសម

---

[125] *ដូចខាងលើ* ជើងទំព័រ ៦២១។

[126] សារអេឡិចត្រូនិករបស់ លឹម ស៊ុយហុង ចំណងជើងថា “សំណើសុំពន្យារពេលដាក់បញ្ជីសាក្សី និង អ្នកជំនាញ តាមវិធាន ៨០ នៃវិធានផ្ទៃក្នុង” ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២១។

[127] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ឯកសារ D270។

[128] ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/4 កថាខណ្ឌ ១៨។

ស្រប[129]។ ខណៈកាលពីមុន មានការជ្រើសរើសយកការអត់ធ្មត់តាមផ្លូវតុលាការ "នៅឱកាសកើតផលពីសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២" ស.ច.ស. ស្ថិតក្នុងករណីបន្ទាន់បង្ខំបានដឹងថា មានភាពចាំបាច់ដែលត្រូវរម្លឹកដល់សមភាគីរបស់ពួកគេនៅ អ.ប.ជ. អំពីភារកិច្ចរបស់ពួកគេ តាមក្រមអភិសមាចារតុលាការជាតិរៀងៗខ្លួន និង អំពីច្បាប់ទូទៅស្តីពីការបរិហារ និង បង្អាច់កេរ្តិ៍ ក្នុងការចោទប្រកាន់ ស.ច.ស. ថា បានបង្វែរដំណើរការយុត្តិធម៌នោះ តាមរយៈការគេចវេសដោយចេតនាពីយន្តការដោះស្រាយជម្លោះ[130]។ កាលនោះ ស.ច.ស. បានពន្យល់លម្អិតអំពីហេតុការណ៍ ដែលនាំទៅដល់ការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា ការយល់ឃើញរបស់ពួកគាត់អំពីភាពត្រឹមត្រូវ និង ផលប៉ះពាល់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី ០០៤/២ ហើយនិងការយល់ឃើញរបស់ពួកគាត់អំពីឧបាស្រ័យដែលមានចំពោះ អ.ប.ជ. ក្នុងការដោះស្រាយភាពទាល់ច្រកផ្នែកនីតិវិធីបច្ចុប្បន្ន[131]។

៤០. ស.ច.ស. បានយល់ឃើញថា មិន"មានចំណុចណាមួយ ទោះអ្វីក៏ដោយ ក្នុងការបង្កឱ្យមាននីតិវិធីខ្វែងយោបល់គ្នាលើយុត្តាធិការនៅចំពោះមុខ អ.ប.ជ. ឡើយ ព្រោះលទ្ធផលគឺជាការបញ្ចប់ ដែលចៀសមិនរួចនោះឡើយ"[132]។ ការ"ធ្វើដូច្នេះគឺមានន័យថា ជាការពន្យាពេលដែលមិនចាំបាច់ និង ការចំណាយពេលវេលា និង ធនធានដោយឥតប្រយោជន៍"[133] ព្រោះ "បើទោះបីជាពួកយើងបានស្នើសុំ អ.ជ.ប. ឱ្យចេញសេចក្តីសម្រេចលើបញ្ហាភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ពីគ្នាក្តី ក៏ប្រហែលជាពួកយើងគួរទទួលបានព័ត៌មានមកវិញថា នេះមិនមែនជានីតិវិធីនៃការខ្វែងយោបល់គ្នានោះទេ តែជាសំណើសុំមតិប្រឹក្សា ជាអ្វីដែល អ.ប.ជ. ... បដិសេធជារៀងរហូត មិនធ្វើការពិចារណា"[134]។

---

[129] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចរបស់ ស.ច.ស. លើការបញ្ជូនសំណុំរឿង ០០៣") កថាខណ្ឌ ២៨។

[130] *ដូចខាងលើ* កថាខណ្ឌ ៩-១៤។

[131] *ដូចខាងលើ* កថាខណ្ឌ ១៥-២៥។

[132] *ដូចខាងលើ* កថាខណ្ឌ ១៥។

[133] *ដូចខាងលើ* កថាខណ្ឌ ១៥។

[134] *ដូចខាងលើ* កថាខណ្ឌ ២០ ដែលដកស្រង់ *រឿងក្តី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧-៨។

៤១. ស.ច.ស. ក៏បានកត់សម្គាល់ផងដែរថា អ.ប.ជ. កាលពីដើមខែសីហា ឆ្នាំ ២០១៤ ត្រូវបានស្នើសុំឱ្យផ្តល់ការយល់ឃើញផ្ទាល់ខ្លួនលើបញ្ហាអង្គច្បាប់នេះ ក្នុងករណីដែល ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នា ដោយផ្អែកលើការខ្វែងយោបល់របស់ ស.ច.ស.[135]។ អ.ប.ជ. បានយល់ឃើញថា "គម្រូមធ្យោបាយ (សេណារីអូ) ដែលប្រមើលមើលនៅក្នុងសំណើនោះ ... [គឺ] សម្មតិកម្ម" គឺសន្មត ហើយ អញ្ចឹងឯង ទើប អ.ប.ជ. បានយល់ឃើញថា ខ្លួន"ពុំមានយុត្តាធិការវែកញែកបញ្ហាដែលជាសម្មតិកម្ម ឬ ផ្តល់នូវមតិយោបល់ណែនាំនោះទេ"[136]។

៤២. ស.ច.ស. "ដូចគ្នានឹងអង្គជំនុំជម្រះតុលាការកំពូល .... [បាន]វង្វេងវង្វាន់លែងដឹងថា តើចៅក្រមនៃ អ.ប.ជ. អាចលើកឡើង*រួមគ្នា*ដោយរបៀបណា នៅក្នុងរឿងក្តី ០០៤/២ ថា ដីកាដំណោះស្រាយដាច់ពីគ្នា គឺខុសច្បាប់យ៉ាងច្បាស់ក្រឡែត និង ជាការរំលោភបំពានទៅលើក្របខណ្ឌរបស់ អ.វ.ត.ក ដោយមានតែចៅក្រមជាតិ និង ចៅក្រមអន្តរជាតិ បន្តពិភាក្សាលើអង្គសេចក្តី និង យល់ផ្សេងគ្នា ក្នុងការសម្រេចតម្កល់ដីកាដំណោះស្រាយ ដែលត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់ពួកគេនោះ"[137]។

៤៣. ស.ច.ស. បានពិចារណាថា ប្រសិន "បើកំហុសរបស់[ពួកខ្លួន] ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា អាក្រក់បំផុតដូចបានរៀបរាប់យ៉ាងវែងដោយ អ.ប.ជ. នៅក្នុងសេចក្តីពិចារណាទាំងពីរនោះ ជាការដ៏ត្រឹមត្រូវបំផុត ដែលដីកាដំណោះស្រាយ*ទាំងពីរ* គួរតែត្រូវបានបដិសេធចោលភ្លាមៗ និង ជាឯកច្ឆន្ទ ដោយសារតែវិការៈនីតិវិធីដ៏ធ្ងន់ធ្ងរ ដោយ អ.ប.ជ. មិនចាំបាច់ចំណាយពេលវេលាលើការពិភាក្សាអំពីអង្គសេចក្តីឡើយ ហើយរឿងក្តីត្រូវបង្វិលត្រឡប់មកពួកខ្លួន ដោយមានសេចក្តីណែនាំមិនឱ្យមានដីកាដំណោះស្រាយដាច់ពីគ្នា"[138]។ "កំហុសនីតិវិធីនៃដីកាដែលមានស្ថានទម្ងន់បែបនេះនៅក្នុងសេចក្តីសម្រេចណាមួយ នៅអំឡុងការស៊ើបអង្កេត ប្រាកដណាស់នឹងនាំទៅដល់ការជាមោឃៈនៃដីកានោះ ហើយចាំបាច់ត្រូវលុបចេញពីសំណុំរឿង ដោយសារតែអសារឥតការ"[139]។

៤៤. ពាក់ព័ន្ធនឹងអានុភាពផ្លូវច្បាប់នៃសេចក្តីពិចារណារបស់ អ.ប.ជ. ស.ច.ស. បានយល់ឃើញថា មាន "តែផ្នែករួមគ្នានៃសេចក្តីពិចារណារបស់ អ.ប.ជ. ប៉ុណ្ណោះ ដែលអាចមានអានុភាពចងកាតព្វកិច្ច

---

[135] សេចក្តីសម្រេចរបស់ ស.ច.ស. លើការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២០។

[136] *ដូចខាងលើ* កថាខណ្ឌ ២០។

[137] *ដូចខាងលើ* កថាខណ្ឌ ២១។

[138] *ដូចខាងលើ* កថាខណ្ឌ ២០។

[139] *ដូចខាងលើ* កថាខណ្ឌ ២១។

ព្រោះផ្នែកនេះត្រូវបានព្រាងជាឯកច្ឆន្ទ"[140]។ ការ"ទទូចទាមទាររបស់ចៅក្រមអន្តរជាតិទាំងនៅក្នុងរឿងក្តី ០០៤/២ និង រឿងក្តី ០០៣ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយដីកាសម្រេចលើកលែងចោទប្រកាន់ គឺ*ហួសពីសមត្ថកិច្ច* ឬ "មិនអនុលោមតាម" ច្បាប់ជាធរមាននោះ គឺគ្រាន់តែដោយសារលទ្ធផលនោះ ស្របទៅតាមវិធានរកសំឡេងមិនបាន គឺពិតជាមិនគួរឱ្យជឿបានឡើយ ដោយសារចៅក្រមជាតិ បើទោះបីជាអនុវត្តផ្ទុយទៅនឹងអ្វីដែលពួកគេបានសម្រេចរួមគ្នាជាមួយចៅក្រមអន្តរជាតិក្តី តែបែរជាជ្រើសរើសការធ្វើដំណើរក្នុងទិសដៅផ្ទុយគ្នាទៅវិញ"[141]។ ក្រៅពីនេះ ស.ច.ស. ក៏បានយល់ឃើញថា "ចៅក្រមជាតិនៃ អ.ប.ជ. "ធ្វើការបត់ត្រឡប់ក្រោយជាភាសាហៅថា U-turn" ដោយលើកឡើងក្នុងរឿងក្តី ០០៣ ថា "*ដីកាដំណោះស្រាយទាំងពីរ មានសុពលភាពនោះ* គឺមិនអាចផ្លាស់ប្តូរសេចក្តីសន្និដ្ឋាននោះឡើយ ព្រោះពួកគាត់នៅតែបន្ត ហើយផ្តល់ដោយផ្ទាល់នូវសេចក្តីណែនាំ*រដ្ឋបាល*ថា សំណុំរឿង ០០៣ ត្រូវដាក់បញ្ចូលទៅក្នុងបណ្ណសារ"[142]។

៤៥. ស.ច.ស. បានផ្តល់ដំណោះស្រាយចំនួនបី ដើម្បីបំបែកភាពទាល់ច្រកក្នុងរឿងក្តី ០០៣ ដោយការកត់សម្គាល់ថា អ.ប.ជ. មានឱកាសអនុវត្តដំណោះស្រាយទាំងនោះរួចហើយ៖ (ក) "ឬ ជាឯកច្ឆន្ទបង្វិលត្រឡប់សំណុំរឿងមកពួកគាត់វិញ ដោយសារតែកំហុសនីតិវិធីធ្ងន់ធ្ងរ ហើយមិនចាំបាច់ពាក់ព័ន្ធជាមួយអង្គសេចក្តីឡើយ ដោយមានសេចក្តីណែនាំឱ្យចេញដីកាដំណោះស្រាយតែមួយរួមគ្នា" (ខ) ឬក៏ "បំពេញកិច្ចដោយខ្លួនឯងផ្ទាល់ជាឯកច្ឆន្ទ អនុវត្តវិធានរកសំឡេងមិនបាន ហើយបញ្ជូនរឿងទៅជំនុំជម្រះ" (គ) ឬមួយ "ដោយសារតែការខ្វែងយោបល់គ្នា នៅមានជាក់ស្តែងនឹង អ.ប.ជ. ... ធ្វើការបញ្ចប់រឿងក្តី ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចជាស្ថាពរ ក្នុងរឿងក្តី ០០៤/២"[143]។

៤៦. ***មេធាវីការពារក្តី និង ស.ព.អ. ប្តឹងទៅ អ.ប.ជ. ស្នើសុំឱ្យបញ្ចប់រឿងក្តី ០០៣។*** នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ មេធាវីការពារក្តីបានស្នើសុំឱ្យ អ.ប.ជ. បញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ ដើម្បីជៀសវាងការរំលោភបំពាននីតិវិធី និង ភាពអយុត្តិធម៌[144]។ នៅថ្ងៃទី

[140] *ដូចខាងលើ* កថាខណ្ឌ ២១។

[141] សេចក្តីសម្រេចរបស់ ស.ច.ស. លើការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៣។

[142] *ដូចខាងលើ* កថាខណ្ឌ ២៤។

[143] *ដូចខាងលើ* កថាខណ្ឌ ២៥។

[144] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D272 (ត្រូវបានជូនដំណឹងនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១)។

២១ ខែ មិថុនា ឆ្នាំ ២០២១ ស.ព.អ. បានស្នើសុំឱ្យ អ.ប.ជ. ចេញ "សេចក្ដីសម្រេចជាស្ថាពរមួយ ដែលយល់ស្របគ្នា ដោយការបញ្ជាក់បង្ហាញថា មាស មុត ត្រូវបានចោទប្រកាន់ និង បង្គាប់ឱ្យ បញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[145]។ ទោះបីជាមានការស្នើសុំ ដំណោះស្រាយផ្សេងពីគ្នាក៏ដោយ ក៏ ស.ព.អ. និង មេធាវីការពារក្ដី បានយល់ស្របគ្នាថា អ.ប.ជ. ខកខានមិនបានបំពេញភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការសម្រេចលើបញ្ហា ដែលខ្លួនត្រូវបាន ប្ដឹងឱ្យទទួលពិនិត្យ[146]។

៤៧. ***អ.ប.ជ. បដិសេធសំណើទាំងពីរ ដោយការអះអាងថា ខ្លួនបានបំពេញភារកិច្ចតាមផ្លូវតុលាការ របស់ខ្លួនរួចរាល់ហើយ។*** នៅថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០២១ អ.ប.ជ. បានបដិសេធសំណើរបស់ មេធាវីការពារក្ដី និង ស.ព.អ. ដែលស្នើសុំឱ្យសម្រេចរឿងក្ដី ០០៣ ដោយការយល់ឃើញថា "ពាក្យ សុំរបស់ម្ចាស់បណ្ដឹងបានបំពេញរួចហើយ តាមសេចក្ដីពិចារណានៅក្នុងរឿងក្ដី ០០៣"[147]។ ផ្ទុយពី ស.ច.ស. បើតាម អ.ប.ជ. វិញ ពុំមានអត្ថបទណាមួយដែលតម្រូវឱ្យ អ.ប.ជ. ឈានដល់សេចក្ដី សម្រេចជាឯកច្ឆន្ទទេ[148]។ ដោយបានចេញសេចក្ដីពិចារណារបស់ខ្លួន អ.ប.ជ. "បានបំពេញភារកិច្ច របស់ខ្លួនដោយប្រសិទ្ធភាព" ហើយបានពន្យល់ថា ពេលនេះគឺ ស.ច.ស. ដែល"ជាអ្នកទទួលខុស ត្រូវដើម្បីចាត់ការសំណុំរឿង ដោយអនុលោមតាមវិធាន ៧៧(១៣) និង ៧៧(១៤) នៃវិធានផ្ទៃក្នុង" និង "អនុវត្តតាមសេចក្ដីពិចារណាភ្លាមៗជាបន្ទាន់"[149]។ នៅមានទៀត អ.ប.ជ. បានពិចារណាថា ស.ច.ស. បាន"សម្រេចទុកជាមុនលើ "ជោគវាសនានៃសំណុំរឿងនេះ" ក្នុងករណីសំណុំរឿងនោះ ត្រូវបញ្ជូនត្រឡប់មកនៅចំពោះមុខពួកគេវិញក្ដី" ដោយការច្រានចោលសំណើរបស់ ស.ព.អ. សុំ បញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ និង [បាន]"ចោទសួរពីហេតុផលរបស់ [ស.ច.ស.អ.] ដែល

---

[145] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D271/1 កថាខណ្ឌ ១។

[146] សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D272 កថាខណ្ឌ ៤៦។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D271/1 កថាខណ្ឌ ១៧, ៥១។

[147] សេចក្ដីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្ដី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិ វិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D271/5 & D272/3 ("សេចក្ដីសម្រេចរួមរបស់ អ.ប.ជ.") កថាខណ្ឌ ៧២។

[148] *ដូចខាងលើ* កថាខណ្ឌ ៦៨។

[149] *ដូចខាងលើ* កថាខណ្ឌ ៧២។

បន្ទាប់ពីមានសេចក្តីបង្គាប់ឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ... បន្ទាប់ពីការស៊ើបអង្កេតរយៈពេលអស់ដប់ឆ្នាំ នាពេលនេះ ស្រាប់តែប្រកាស ក្រោមមូលដ្ឋានស្របច្បាប់ស្រមើស្រមៃថា ខ្លួនមិនអាចបញ្ជូនរឿងទៅអង្គជំនុំជម្រះ និង ត្រៀមរួចរាល់ជាសក្តានុពល បញ្ចូលរឿងក្តីទៅក្នុងបណ្ណសារ"[150]។ ការបដិសេធថា "មិនជាប់ស៊ុមគ្រលុំនឹងកិច្ចភាន់ច្រឡំរបស់ [ស.ច.ស.] កន្លងទៅ ឬ សំណើដែលបានអនុញ្ញាតរួចមកហើយ" នោះ អ.ប.ជ. បានថ្លែងថា ខ្លួនមានបំណង"ប្រកាន់តាមសេចក្តីពិចារណារបស់ខ្លួន"[151]។

៤៨. ***ស.ព.អ. បានផ្ញើសារអេឡិចត្រូនិក នូវសំណើសុំដាក់សារណាតែមួយភាសា។*** នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០២១ ស.ព.អ. បានផ្ញើសារអេឡិចត្រូនិកធ្វើសំណើសុំដាក់សារណាជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ ដោយការបញ្ជាក់អះអាងថា ការអនុញ្ញាតបែបនេះគឺជាការចាំបាច់ សម្រាប់ដាក់សារណារបស់ខ្លួន ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ អ.ប.ជ.[152]។ នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២១ ស.ព.អ. បានស្នើផ្លូវការសុំដាក់តែមួយភាសា តាមរយៈសារអេឡិចត្រូនិក ដោយអះអាងថា "សារអេឡិចត្រូនិកគឺជាមធ្យោបាយតែមួយគត់ដែលគាត់អាចមាន" ដោយសារតែផ្នែកគ្រប់គ្រងតុលាការបានជូនដំណឹងថា ពួកគេមិនអាចទទួលសារណារបស់គាត់ ដោយមិនមានសេចក្តីណែនាំបន្ថែមពីអង្គជំនុំជម្រះតុលាការកំពូលឡើយ"[153]។

## II. ភាពអាចទទួលយកបាន

៤៩. អង្គជំនុំជម្រះតុលាការកំពូល មានយុត្តាធិការដែលជាប់ជាមួយ ក្នុងការយល់ឃើញថា សំណើនេះអាចទទួលយកបាន ដើម្បីធានាដំណើរការគ្រប់គ្រងយុត្តិធម៌ឱ្យល្អ និង ត្រឹមត្រូវ តាមវិធាន ២១ (១) នៃវិធានផ្ទៃក្នុង[154]។ អង្គជំនុំជម្រះតុលាការកំពូល "ពិចារណាថា នេះជាកាតព្វកិច្ចក្នុងនាមជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និង តុលាការជាន់ខ្ពស់ចុងក្រោយ ក្នុងការផ្តល់ឧបាស្រ័យតាមផ្លូវច្បាប់ និង

---

[150] *ដូចខាងលើ* កថាខណ្ឌ ៧៥។

[151] *ដូចខាងលើ* កថាខណ្ឌ ៧៦។

[152] សារអេឡិចត្រូនិករបស់ ស.ព.អ. ចំណងជើងថា "សំណើសុំដាក់សំណើសុំការពិចារណាមួយភាសា" ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០២១។

[153] សារអេឡិចត្រូនិករបស់ ស.ព.អ. ចំណងជើងថា "សំណើសុំការអនុញ្ញាតដាក់សំណើសុំការពិចារណាតែមួយភាសា" ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២១។

[154] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥៨-៦៥។

ការ សម្រេចចុងក្រោយនៃរឿងក្តី ដែលលក្ខន្តិកៈ ឬ ច្បាប់ ពុំមានចែង ឬ មិនច្បាស់លាស់"[155] ជាពិសេស ក្នុងករណីការជាប់គាំងបង្ហាញពី "ភាពបរាជ័យនៃប្រព័ន្ធតុលាការក្នុងការផ្តល់ឧបាស្រ័យ"[156]។

៥០. "ជាក់ស្តែង គ្មានសមភាពនៃមធ្យោបាយតទល់ក្តីទេ ប្រសិនបើមានតែភាគីអយ្យការ តែគ្មានភាគីជនជាប់ចោទ ក្នុងការប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចជាក់លាក់មួយនោះ"[157]។ យ៉ាងណាក្តី ក៏ការរង់ចាំឱ្យ ស.ព.អ. ប្តឹងសាទុក្ខនឹងសេចក្តីសម្រេចរបស់ អ.ប.ជ. ឬ សាអេឡិចត្រូនិករបស់ អ.ជ.ស.ដ. ដែលបដិសេធបញ្ជីឈ្មោះសាក្សីរបស់គាត់ គ្រាន់តែជាលេសប៉ុណ្ណោះ ពីព្រោះគ្មានវិធានណាមួយដែលអនុញ្ញាតឱ្យប្តឹងសាទុក្ខចំពោះករណីបែបនេះឡើយ។ នៅក្នុងរឿងក្តី ០០៤/២ អង្គជំនុំជម្រះតុលាការកំពូល "[បាន]ប្រើប្រាស់ឆន្ទានុសិទ្ធ ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និង ភាពត្រឹមត្រូវ ទទួលធ្វើការពិចារណាបណ្តឹងសាទុក្ខភ្លាមៗ[របស់ ស.ព.អ.]" ទោះបីជាសេចក្តីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. មិនបានចាត់ទុកជាសេចក្តីសម្រេច "ដើម្បីធានាថា សច្ចភាព និង អវសានភាពផ្លូវច្បាប់ត្រូវទទួលបានក្នុងការកំណត់នៃរឿងក្តី[នេះ] និង បញ្ជាក់នូវសុចរិតភាពនៃស្ថាប័ន អ.វ.ត.ក."[158]។ អង្គជំនុំជម្រះបានពិចារណាថា ដំណោះស្រាយនៅក្នុងកាលៈទេសៈបែបនេះ គឺជា"ភាពចាំបាច់លើសលុប"[159]។

៥១. ដើម្បីជាផលប្រយោជន៍នៃសេដ្ឋកិច្ចតុលាការ អង្គជំនុំជម្រះត្រូវទទួលយកសំណើនេះ។ ការទទួលយកសំណើនេះនឹងកាត់បន្ថយចំនួននៃសំណើសុំពិចារណា ដែលដាក់នៅចំពោះមុខ ស.ច.ស. ចំពោះមុខ អ.ប.ជ. និង ចុងក្រោយ ចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

## III. ឧទ្ទិករណ៍

៥២. លោក មាស មុត មានសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើគ្នានៅចំពោះមុខ អ.វ.ត.ក.។ មិនខុសពីរឿងក្តី ០០៤/២ ឡើយ គឺពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលសុពល ត្រូវបញ្ជូនរឿងក្តី ០០៣

---

[155] *ដូចខាងលើ* កថាខណ្ឌ ៦៤។

[156] *ដូចខាងលើ* កថាខណ្ឌ ៦៤។

[157] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស យោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពនៅចំពោះមុខតុលាការ និង សាលាជម្រះក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៣។

[158] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៥។

[159] *ដូចខាងលើ*។

ទៅជំនុំជម្រះនោះទេ។ ឬក៏គ្មានហេតុផលច្បាស់លាស់ ដើម្បីងាកចេញពីសំអាងហេតុលើអង្គច្បាប់ និង លើអង្គហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសេចក្ដីសម្រេចបញ្ចប់សំណុំរឿង ០០៤/២ នោះឡើយ។ ខណៈដែល ស.ច.ស. បានកំណត់ថា រឿងក្ដី ០០៣ បានទុំជោរដល់កាលបញ្ចប់ហើយនោះ សេចក្ដីបង្គាប់បញ្ចប់របស់អង្គជំនុំជម្រះតុលាការកំពូល គួរតែចេញដើម្បីជាផលប្រយោជន៍យុត្តិធម៌ និង កេរដំណែលកាន់តែប្រពៃរបស់ អ.វ.ត.ក.។

## ក. លោក មាស មុត មានសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាព

៥៣. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិដូចគ្នា"។ គោលការណ៍រដ្ឋធម្មនុញ្ញភាពនៃការប្រព្រឹត្តដោយស្មើភាព ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌ អ.វ.ត.ក. ក្នុងវិធាន ២១(១)(ខ) ដែលតម្រូវថា "បុគ្គលទាំងឡាយដែលរកឃើញថាស្ថិតក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ដូចគ្នាចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"។ គណៈកម្មាធិការសិទ្ធិមនុស្សពន្យល់ថា គោលការណ៍នេះ "តម្រូវថា រឿងក្ដីស្រដៀងគ្នាត្រូវដោះស្រាយដោយដំណើរការនីតិវិធីស្រដៀងគ្នា"[160]។ "គោលដៅសត្យានុម័ត និង មូលដ្ឋានសមហេតុផល ត្រូវតែផ្ដល់ជូន" ដើម្បីបង្ហាញអំពីភាពខុសគ្នានៅក្នុងនីតិវិធី[161]។

៥៤. មិនមាន "មូលដ្ឋានសត្យានុម័ត និង ពាក់ព័ន្ធ" ដើម្បីប្រព្រឹត្តចំពោះលោក មាស មុត ខុសពី អោ អាន នោះទេ។ លោក មាស មុត និង អោ អាន ត្រូវបានស៊ើបអង្កេតដោយ ស.ច.ស.ជ. ម្នាក់ និង ដោយ ស.ច.ស.អ. ចំនួនប្រាំនាក់ លើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និង ការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៥[162]។ ការស៊ើបអង្កេតក្នុងរឿងក្ដី ០០៣ ប្រឆាំង លោក មាស មុត និង រឿងក្ដី ០០៤/២ ប្រឆាំង អោ អាន ត្រូវបានបញ្ចប់ដោយការចេញដីកាដំណោះស្រាយផ្ទុយគ្នា ដោយសារតែការខ្វែងយោបល់គ្នារវាង ស.ច.ស. ទៅ

---

[160] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស យោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពនៅចំពោះមុខតុលាការ និង សាលាជម្រះក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៤។

[161] *សូមមើល ដូចខាងលើ* ដែលយោងលើ *រឿងក្ដី Weiss ទល់នឹង ប្រទេសអូទ្រីស* សំណុំរឿងលេខ ១០៨៦/២០០២ កថាខណ្ឌ ៩.៦។ សម្រាប់ឧទាហរណ៍មួយផ្សេងទៀតនៃការរំលោភលើគោលការណ៍សមភាពនៃមធ្យោបាយការពារក្ដី *សូមមើល រឿងក្ដី Robinson ទល់នឹង ប្រទេសចាម៉ៃកា* សំណុំរឿងលេខ ២២៣/១៩៨៧ កថាខណ្ឌ ១០.៤។

[162] *ប្រៀបធៀប រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៦ ខែសីហ ឆ្នាំ ២០១៨ ឯកសារ D360 KH ERN 01588970-01588977 *ជាមួយនឹង*ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 ទំព័រ ៤២២-៤៣១។

លើករណីថា តើសំណុំរឿងនេះស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែរឬទេ[163]។

៥៥. ដីកាដំណោះស្រាយទាំងពីរក្នុងរឿងក្តី ០០៣ ដូចក្នុងរឿងក្តី ០០៤/២ ដែរ គឺ "មានទិសដៅផ្ទុយគ្នាទាំងស្រុង និង ឈានដល់ដំណាក់កាលនេះ កើតចេញពីការវិភាគចំនួនពីរដោយយកចិត្តទុកដាក់លើអំពើ ដែលត្រូវបានសន្មតថា ជារបស់ជនសង្ស័យតែមួយដូចគ្នា ទីកន្លែងឧក្រិដ្ឋកម្មតែមួយ និង ពេលវេលាតែមួយដូចគ្នា"[164]។ ការខ្វែងយោបល់គ្នាដែលមិនអាចសម្របសម្រួលបានរបស់ ស.ច.ស. លើបញ្ហាថាតើលោក មាស មុត "គួរគប្បីត្រូវបានស៊ើបអង្កេត*ដែរឬទេ* បាននាំ ស.ច.ស. ដល់ការចុះបញ្ជីជាផ្លូវការនូវការខ្វែងយោបល់គ្នាមួយចំនួនជាមូលដ្ឋាន និង ជៀសពុំរួចដល់ការចេញដីកាដំណោះស្រាយដាច់ពីគ្នា" ដូចដែលបានធ្វើឡើងចំពោះករណី អោ អាន ដែរ[165]។ "ការខ្វែងយោបល់គ្នាទាំងនេះ ដែល"ហាក់បីដូចជាការប្រកាន់នូវគំនិតរឹងត្អឹង និង ខ្លាំងក្លារៀងៗខ្លួន បច្ចុប្បន្ន បាននាំទៅរកភាពទាល់ច្រក" នៅក្នុងរឿងក្តី ០០៣ ដូចនៅក្នុងរឿងក្តី ០០៤/២ ដែរ[166] ដោយ អ.ប.ជ. ខកខានមិនបានទទួលសំឡេងភាគច្រើនលើសលុបនៅក្នុងរឿងក្តីទាំងពីរ ដើម្បីបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ ក៏លើកលែងចោទប្រកាន់។

៥៦. លោក មាស មុត ស្ថិតក្នុងស្ថានភាពដូច អោ អាន នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា រឿងក្តីរបស់គាត់គួរតែត្រូវបានបញ្ចប់ ពោលគឺការចេញដីកាដំណោះស្រាយខុសច្បាប់ចំនួនពីរ ដោយពុំទទួលបានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. ដើម្បីតម្កល់ ឬ ច្រានចោលដីកាណាមួយ។ ភាពខុសគ្នាផ្នែកនីតិវិធីតែមួយគត់គឺថា ស.ព.អ. មិនបានប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូល បន្ទាប់ពី អ.ជ.ស.ដ. បដិសេធបញ្ជីឈ្មោះសាក្សីរបស់គាត់ តែបែរជាប្តឹងទៅ ស.ច.ស. និង ក្រោយមក ប្តឹងទៅ អ.ប.ជ. ទៅវិញ។

---

[163] *សូមមើល ខាងលើ* កថាខណ្ឌ ១-៤៨។ *សូមមើល ផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥៩, ៦២។

[164] *សូមមើល ខាងលើ* កថាខណ្ឌ ៤-១១។ *សូមមើល ផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦២។

[165] *សូមមើល ខាងលើ* កថាខណ្ឌ ៤-១១។ *សូមមើល ផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦២។

[166] *សូមមើល ខាងលើ* កថាខណ្ឌ ៣៩-៤១។ *សូមមើល ផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦២។

## ខ. ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលសុពលនៅក្នុងរឿងក្តី ០០៣

៥៧. នៅពេលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធមិនឱ្យ លោក មាស មុត ធ្វើអន្តរាគមន៍ក្នុងរឿងក្តី ០០៤/២ អង្គជំនុំជម្រះបានពិចារណាសំណើរបស់គាត់ថាជា "ការរំពឹងទុក" និង ថាខ្លួនមាន "លទ្ធភាពធ្វើបុរេវិនិច្ឆ័យលទ្ធផលនៃរឿងក្តី"[167] ដោយសារតែ តាមការសន្មត អ.ប.ជ ត្រូវគោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល នៅពេលចេញសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៣។

៥៨. នៅមានទៀត គឺ អ.ប.ជ មិនបានគោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការបញ្ចប់រឿងក្តី ០០៤/២ និង មិនបានផ្តល់ "ការសម្រេចចុងក្រោយជាក់លាក់" ក្នុងការដោះស្រាយរឿងក្តី ០០៣ បន្ទាប់ពីបានប្រកាសថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាគឺខុសច្បាប់[168]។ ចៅក្រមជាតិនៃ អ.ប.ជ. នៅពេលអះអាងថា រឿងក្តីនេះគួរតែបញ្ជូលទៅក្នុងបណ្ណាសារ បានពិចារណាថា ដីកាដំណោះស្រាយទាំងពីរមាន "តម្លៃស្មើគ្នា" ចំណែកចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយបានយល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចាត់ទុកជាមោឃៈ និង ឥតបានការ[169]។ អ.ប.ជ. មិនបាន ៖ (ក) បញ្ជូនរឿងក្តីនេះទៅ ស.ច.ស. វិញ ជាមួយនឹងសេចក្តីណែនាំឱ្យចេញដីកាដំណោះស្រាយតែមួយនោះឡើយ ឬ (ខ) ស៊ើបអង្កេត និង ចេញដីកាដំណោះស្រាយដែលកែប្រែ ស្របតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនោះឡើយ[170]។

៥៩. បន្ទាប់ពី អ.ប.ជ. ចេញសេចក្តីពិចារណា ស.ច.ស. បានពិចារណាថា អង្គជំនុំជម្រះតុលាការកំពូល "បញ្ជាក់ច្បាស់លាស់នៅក្នុងរឿងក្តី ០០៤/២ ថា អ.ប.ជ. *ត្រូវតែ*ជ្រើសរើសយកដំណោះស្រាយ

---

[167] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអានុភាពដែលនាំឱ្យបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០ ឯកសារ E004/2/2/1 ទំព័រ ៣-៥។

[168] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ទំព័រ ៥៧។

[169] *សូមមើល* ខាងលើ កថាខណ្ឌ ៣១-៣៣។

[170] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១ *ដែលក្នុងចំណោមនោះ* ដកស្រង់សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៣០។

ស្ពាពរមួយសម្រាប់រឿងក្តីនៅចំពោះមុខខ្លួន"[171]។ ការយល់ឃើញថា ខ្លួនពុំមានយុត្តាធិការក្នុងការសម្រេចលើជោគវាសនានៃរឿងក្តី ០០៣ ដោយសារវាកំពុងស្ថិតក្នុងដៃ អ.ប.ជ. នៅឡើយ រង់ចាំការកំណត់ពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ហើយការលើកទឹកចិត្តឱ្យ ស.ព.អ. ប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់ខ្លួន នោះ ស.ច.ស. បានផ្តល់ឱកាសឱ្យ អ.ប.ជ. ដើម្បីបញ្ជាក់បំភ្លឺពីសេចក្តីពិចារណារបស់ខ្លួន[172]។

៦០. នៅពេលផ្តល់ឱកាសឱ្យបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់ខ្លួន ដោយការសម្រេចលើសំណើរបស់មេធាវីការពារក្តី និង ស.ព.អ. ដើម្បីបញ្ចប់ដំណើរការនីតិវិធីមុនពេលជំនុំជម្រះនៅក្នុងរឿងក្តី ០០៣ អ.ប.ជ បានពិចារណាថា ខ្លួន*ពុំ*ចាំបាច់ត្រូវចេញសេចក្តីសម្រេចជាឯកច្ឆ័ន្ទ ដើម្បីកំណត់លើរឿងក្តីនេះទេ[173]។ អ.ប.ជ. ក៏បានបញ្ជាក់ផងដែរថា ខ្លួនមិនអាចរកសំឡេងភាគច្រើនលើសលុបលើបញ្ហាដែលបានបង្ហាញនៅក្នុងសំណើទាំងនេះថា តើត្រូវបញ្ចប់ បិទត្រា និង បញ្ចូលទៅក្នុងបណ្ណសារ ឬថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬទេនោះ[174]។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់ អ.ប.ជ. លើសំណើរបស់ ស.ព.អ. និង មេធាវីការពារក្តី ស.ច.ស. បច្ចុប្បន្ន ពិចារណាថា "ទង្វើករណ៍ណាមួយដែលចៅក្រមទាំងប្រាំនាក់ បានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ. ... នោះត្រូវចាត់ទុកជាបានការ យោងតាមពាក្យពេចន៍ផ្ទាល់របស់ អ.ប.ជ."[175]។

៦១. មន្ទិលសង្ស័យណាមួយ ដែលថា អ.ប.ជ. ដោយឯកច្ឆ័ន្ទបានតម្កល់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ត្រូវបានដកហូតចេញ ៖ ដីកាដំណោះស្រាយទាំងពីរគឺ "មានតម្លៃស្មើគ្នា" ពីព្រោះត្រូវបានចាត់ទុកជា*មោឃៈ និង ឥតបានការ*ដូចគ្នា។ លើកលែងតែអង្គជំនុំជម្រះតុលាការកំពូលរកឃើញហេតុផលច្បាស់លាស់ ក្នុងការងាកចេញពីសំអាងហេតុរបស់ខ្លួននៅក្នុងរឿងក្តី ០០៤/២ បើមិនដូច្នោះទេ លោក មាស មុត ត្រូវទទួលបានអត្ថប្រយោជន៍ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយដែលសុពល អាចបន្តបាននោះទេ ដូច្នេះ រឿងក្តី ០០៣ គួរតែត្រូវបានបញ្ចប់ បើមិនអ៊ីចឹង សិទ្ធិទទួលកិច្ចការពារស្មើភាពនៅក្នុងរដ្ឋធម្មនុញ្ញរបស់

---

[171] សេចក្តីសម្រេចរបស់ ស.ច.ស. លើសំណើសុំឱ្យបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៥។

[172] *ដូចខាងលើ* កថាខណ្ឌ ៤០, ៤៣។

[173] សេចក្តីសម្រេចរួមរបស់ អ.ប.ជ. កថាខណ្ឌ ៦៨។

[174] *ដូចខាងលើ* កថាខណ្ឌ ៧៧។

[175] ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣ កថាខណ្ឌ ២។

លោក មាស មុត នឹងត្រូវបានរំលោភបំពាន[176]។

### គ. គ្មានហេតុផលមាំទាំគួរជឿ ក្នុងការដាកចេញពីសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០៤/២

៦២. អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ទោះបីជាមានការព្រមព្រៀងទាក់ទងនឹងចំនួនជនរងគ្រោះច្រើនក្ដី ក៏ពុំមានការព្រមព្រៀងណាមួយ បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេល ១៣ ឆ្នាំ ដែលថា អោ អាន ស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ ហើយថា ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះណាមួយមានអានុភាពជាក់លាក់ និង អាចអនុវត្តបាន ប្រឆាំងនឹងគាត់ នោះរឿងក្ដី ០០៤/២ គប្បីត្រូវបញ្ចប់[177]។

៦៣. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. មិនផ្ដល់ហេតុផលរឹងមាំ ឬ សំអាងច្បាប់ជាក់លាក់ ដើម្បីដាកចេញពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០៤/២ នោះឡើយ។ ដោយការបកស្រាយខុសលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ទើបបណ្ដាលឱ្យចៅក្រមអន្តរជាតិនៃ អ.ប.ជ. ៖

ក. ខកខានមិនបាន យល់ដឹងទូលំទូលាយថា វិធានបកស្រាយនៃប្រព័ន្ធច្បាប់ស៊ីវិល នីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមាន និង វិធាននីតិវិធីនានា ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិចែងថា កាលណាចៅក្រមមិនមានសិទ្ធិអំណាចចេញសេចក្ដីសម្រេចជាក់លាក់ណាមួយ សេចក្ដីសម្រេចនោះត្រូវចាត់ទុកជាមោឃៈ និង ឥតបានការ[178]។

ខ. ខកខានមិនបាន បែងចែកលក្ខណៈនៃដីកាដំណោះស្រាយដាច់ចេញពីសាលក្រម ដោយដកស្រង់បទដ្ឋានមិនត្រឹមត្រូវនៃការពិនិត្យឡើងវិញចំពោះកំហុសនីតិវិធីលើបណ្ដឹងឧទ្ធរណ៍[179]។

គ. ខកខានមិនបាន កត់សំគាល់ផ្នែករួមនៃសំអាងហេតុ ដើម្បីផ្ដល់ឧត្តមានុភាពដីកាណាមួយក្នុង

---

[176] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២(២) មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី, ៣៥ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(១) មាត្រា ២៦ នៃកតិកាសញ្ញា ICCPR។

[177] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ ឯកសារ E004/2/1/1/2 កថាខណ្ឌ ៦៩។

[178] *សូមមើល* សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន កថាខណ្ឌ ៣១។

[179] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ ជើងទំព័រលេខ ៦០៩។

ចំណោមដីកាដំណោះស្រាយទាំងពីរ ថា មានសុពលភាព ឬ ចាត់ទុកជាបានការ[180]។

ឃ. ខកខានមិនបាន យល់អំពីលក្ខណៈនៃអង្គច្បាប់ (ផ្ទុយពីអង្គហេតុ) នៃបញ្ហា ដែលបានបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍បន្ទាន់ភ្លាមៗរបស់ ស.ព.អ. និង បទដ្ឋាននៃការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះកំហុសឆ្គងទាំងនោះនៅក្នុងបណ្តឹងឧទ្ធរណ៍[181]។

ង. ខកខានមិនបាន ទទួលស្គាល់សិទ្ធិរបស់ជនត្រូវចោទ អនុលោមតាមវិធាន ២១(៤) ក្នុងការឱ្យដំណើរការនីតិវិធី "ត្រូវបានបញ្ចប់ក្នុងរយៈពេលសមស្របមួយ"[182]។ និង

ច. ខកខានមិនបាន យល់ដឹងអំពីនីតិវិធីនៃការជូនដំណឹង និង ការបញ្ជូនសំណុំរឿង ដូចដែលមានចែងនៅក្នុងក្របខ័ណ្ឌរបស់ អ.វ.ត.ក.[183]។

៦៤. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ក៏បានយល់ឃើញដោយភាន់ច្រឡំនៅក្នុងរឿងក្តី ០០៣ ថា វិធាន ៧៧ (១៣)(ខ) ត្រូវយកមកអនុវត្ត ដើម្បីបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅ អ.ជ.ស.ដ.។ វិធាន ៧៧ (១៣) មិនអាចអនុវត្តបានទេ ពីព្រោះពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាព។ ប៉ុន្តែ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ច្រានចោល និង ពិចារណាថា ដីកាដំណោះស្រាយទាំងពីរ *មិន*ត្រូវបានចាត់ទុកជាមោឃៈ និង ឥតបានការក្តី ក៏វិធាន ៧៧ (១៣) មិនអាចអនុវត្តបានទេ ពីព្រោះវិធាននេះគាត់តែងឡើងសម្រាប់ការចេញដីកាដំណោះស្រាយ *តែមួយ*។ អនុលោមតាមវិធាន ៧៧(១៣)(ក) និងវិធាន ៧៧ (១៣) (ខ) ដីកាដំណោះស្រាយទាំងពីរនឹងនៅតែតាមលងបន្តាចជារៀងរហូត ជាស្ថានភាពមួយ ដែល ស.ច.ស. បានយល់ឃើញថា វាផ្ទុយនឹងនីតិរដ្ឋ[184]។

៦៥. ដោយសារមិនមានហេតុផលសត្យានុម័តក្នុងការញែករឿងក្តី ០០៣ ពីរឿងក្តី ០០៤/២ និងដោយ

[180] *ដូចខាងលើ* កថាខណ្ឌ ២៧៤។

[181] *ដូចខាងលើ* កថាខណ្ឌ ២៨០។

[182] *ដូចខាងលើ* កថាខណ្ឌ ២៧៥។ *សូមមើលផងដែរ* វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

[183] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៤៩។

[184] បណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-៤៦។ ការឆ្លើយតបរបស់មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ២២។ សារណាបន្ថែមរបស់ មាស មុត កថាខណ្ឌ ៤៥, ៥០។ សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០២១ ឯកសារ D272 កថាខណ្ឌ ៥២។

សារខ្វះហេតុផលច្បាស់លាស់ណាមួយ ដើម្បីងាកចេញពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០៤/២ លោក មាស មុត ត្រូវតែទទួលបានផលប្រយោជន៍ពីការសម្រេចលើសេចក្ដីពិចារណាផ្នែកអង្គច្បាប់ និង អង្គហេតុ បើមិនដូច្នោះទេ សិទ្ធិទទួលកិច្ចការពារដោយស្មើភាពតាមរដ្ឋធម្មនុញ្ញរបស់ លោក មាស មុត ត្រូវបានរំលោភបំពាន[185]។

### ឃ. ស.ច.ស. បានកំណត់ថា រឿងក្ដី ០០៣ ទុំជោរដល់ដំណាក់កាលត្រូវបញ្ចប់

៦៦. ស.ច.ស. បានពិចារណាថា "ឥឡូវ ពេលវេលាបានមកដល់ហើយ" ដោយសាររឿងក្ដី នាពេលនេះបានឆ្លងកាត់ អ.ប.ជ. ចំនួនពីរដងហើយ ហើយបញ្ហាអង្គច្បាប់ហេតុពាក់ព័ន្ធទាំងអស់ ក៏ត្រូវបានជជែកជាហូរហែដោយភាគីនានាដែរ[186]។ សេចក្ដីសម្រេចរបស់ពួកគេ គឺការសន្និដ្ឋានដែលជៀសមិនរួច ដូចលទ្ធផលនៅ អ.ប.ជ. ប្រសិនបើ ស.ច.ស. បានប្រើប្រាស់យន្តការដោះស្រាយការខ្វែងយោបល់គ្នា[187]។ ដូច ស.ច.ស. បានពន្យល់ ចៅក្រមជាតិនៃ អ.ប.ជ. បានបង្ហាញការយល់ឃើញរបស់ពួកគេជាច្រើនលើកច្រើនសានៅក្នុងរឿងក្ដី ០០៣ រឿងក្ដី ០០៤/២ និង រឿងក្ដី ០០៤/១ ថាពួកគេមិនទទួលយកយុត្តាធិការរបស់ អ.វ.ត.ក. លើជនត្រូវចោទណាម្នាក់ ដែលនៅសេសសល់បន្ទាប់ពីរឿងក្ដី ០០១ និង ០០២ ទេ[188]។ ការប្ដឹងទៅ អ.ប.ជ. "មានន័យថា ជាការពន្យារពេលដែលមិនចាំបាច់ និង ការចំណាយពេលវេលា និង ធនធានដោយឥតប្រយោជន៍" ហើយនៅពេល ស.ច.ស. បានបញ្ចប់ការស៊ើបអង្កេតរបស់ពួកគេ តាមរយៈការចេញដីកាដំណោះស្រាយ នោះយន្តការដោះស្រាយការខ្វែងយោបល់គ្នា ដែលអនុវត្តចំពោះ*ដំណាក់កាលស៊ើបអង្កេត* មិនអាចអនុវត្តបានទេ[189]។ ហើយបើទោះបីជា ស.ច.ស. បានស្នើសុំយោបល់ប្រឹក្សាពី អ.ប.ជ. អំពីនីត្យានុកូល

---

[185] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២(២), មាត្រា ១៣(១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី, ៣៥ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។ វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង។ មាត្រា ១៤(១), មាត្រា ២៦ នៃកតិកាសញ្ញា ICCPR ។

[186] ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣ កថាខណ្ឌ ៦។

[187] *ដូចខាងលើ* កថាខណ្ឌ ១៥។

[188] *ដូចខាងលើ*។

[189] *ដូចខាងលើ* ជំពារ "ដើម" (default) នៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ដែលថា "កិច្ចស៊ើបសួរត្រូវបន្ត" នៅពេលសហព្រះរាជអាជ្ញា ឬ ស.ច.ស. ពុំយល់ស្របគ្នាលើការបន្តរឿងក្ដីទៅមុខ ហើយ អ.ប.ជ. ពុំអាចឈានដល់ការទទួលបានសំឡេងភាគច្រើនលើសលុប អនុវត្តតែនៅក្នុងដំណាក់កាល*ស៊ើបសួរ*ប៉ុណ្ណោះ។ នៅពេលដីកាដីកាដំណោះស្រាយចេញ កិច្ចស៊ើបសួរត្រូវបញ្ចប់ ហើយ ស.ច.ស. *លែងមានភារកិច្ច*ទៀតហើយ។ ចម្លើយរបស់ មាស មុត ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ D266/5 កថាខណ្ឌ

ភាពនៃដីកាដំណោះស្រាយផ្ទុយគ្នាក្ដី ក៏ អ.ប.ជ. នឹងបដិសេធមិនឆ្លើយតប ដូចបានឃើញ នៅពេលមេធាវីការពារក្ដីក្នុងរឿងក្ដី ០០៤ បានស្នើ អ.ប.ជ. សុំការបញ្ជាក់បំភ្លឺ[190]។ បច្ចុប្បន្ន ស.ច.ស. ប្រកាសថា ប្រសិនបើខ្លួនបានទទួលការជូនដំណឹងអំពីទស្សនៈរបស់ អ.ប.ជ. នោះ "រឿងក្ដីដែលនៅសល់ទាំងអស់អាចនឹងត្រូវបានដោះស្រាយ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន តាមរយៈសេចក្ដីសម្រេចរួម ដែល ... អាចត្រឹមតែមានន័យថាជាការបញ្ចប់ភ្លាមៗនូវរឿងក្ដីទាំងអស់ ដែលនៅសេសសល់ បន្ទាប់ពីការរំលត់សំណុំរឿងនៅក្នុងរឿងក្ដី ០០៤/១"[191]។

៦៧. ស.ច.ស. ពិចារណាថា "ពុំឃើញមានទិដ្ឋភាពថ្មីណាមួយទំនងនឹងចេញនោះទេ" ពីព្រោះ "បញ្ហាតែមួយគត់ដែលនៅសល់ ដើម្បីកំណត់នោះគឺថាតើ [ស.ច.ស] មានយុត្តាធិការនៅសេសសល់ ដើម្បីបញ្ចប់រឿងក្ដីនេះដែរឬទេ"[192]។ "លទ្ធភាពដែលថា ស.ព.អ. អាចចង់ប្ដឹងទៅ អ.ជ.ត.ក" ក៏ប៉ុន្តែសំណើបែបនេះត្រូវបានកំណត់លក្ខណៈថាជា"*សំណើសុំបញ្ចប់* ដូចក្នុងរឿងក្ដី ០០៤/២"[193]។ ស.ច.ស. គ្រាន់តែរង់ចាំសំណើសុំការពិចារណាទៅលើករណីថា តើ*ពួកគេ*មានយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់រឿងក្ដីនេះដែរឬទេ មុនពេលស្ដាប់យោបល់ពីអង្គជំនុំជម្រះតុលាការកំពូល[194]។

៦៨. ស.ច.ស. "មិនចង់ឱ្យគេដាក់ក្នុងស្ថានភាពបែបនោះឡើយ" គឺថា បញ្ចប់រឿងក្ដីមុនពេលអង្គជំនុំជម្រះតុលាការប្រកាសពីទស្សនៈយល់ឃើញរបស់ពួកគេ ប៉ុន្តែបានពិចារណាថា "ជាការចាំបាច់

---

១៩។ ការឆ្លើយតបរបស់មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៩ ឯកសារ D267/12 កថាខណ្ឌ ៣៥។ *សូមមើលផងដែរ រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 ("សាលដីកាក្នុងរឿងក្ដី ០០៣") កថាខណ្ឌ ៦៥។ *ទស្សនៈ*របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី ០០១ ទាក់ទងនឹងការខ្វែងយោបល់គ្នារវាង ស.ច.ស. ទាំងពីរនៅក្នុងបរិបទនៃយន្តការដោះស្រាយវិវាទ *មុនពេល* ស.ច.ស. ចេញដីកាដំណោះស្រាយ ឧទា. នៅពេល "*ស្នើសុំ*ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាសម្រេចលើកលែងចោទប្រកាន់"។ (ការគូសបញ្ជាក់បន្ថែម)

[190] ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣ កថាខណ្ឌ ១៩-២០។

[191] *ដូចខាងលើ* កថាខណ្ឌ ១៩។

[192] *ដូចខាងលើ* កថាខណ្ឌ ៦។

[193] *ដូចខាងលើ* កថាខណ្ឌ ៧ (ការគូសបញ្ជាក់បន្ថែម)។

[194] *ដូចខាងលើ* កថាខណ្ឌ ៦។

ដើម្បីសង្កត់ធ្ងន់ថា នីតិរដ្ឋពិតជាមានតម្លៃ ហើយថារឿងក្តីត្រូវតែនៅបន្តជាប់គាំង”[195]។ ដោយហេតុថា គោលជំហររបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងឋានានុក្រម អ.វ.ត.ក. គឺជាតុលាការចុងក្រោយ និង មានភារកិច្ចក្នុងការនាំមកនូវតម្លាភាព អវសានភាព និង “ផ្តល់ឧបាស្រ័យតាមផ្លូវច្បាប់ និង ធ្វើការកំណត់ចុងក្រោយក្នុងរឿងក្តី ដែលលក្ខន្តិកៈ ឬ ច្បាប់ ពុំមានចែង ឬ មិនច្បាស់លាស់”[196] នោះដីកាបញ្ចប់មួយពីអង្គជំនុំជម្រះតុលាការកំពូល និង ដីកាបង្គាប់ឱ្យ ស.ច.ស. បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ នឹងបម្រើផលប្រយោជន៍យុត្តិធម៌ និងកេរដំណែលរបស់ អ.វ.ត.ក. កាន់តែប្រសើរ។ អង្គជំនុំជម្រះតុលាការកំពូលក៏អាចរារាំងមិនឱ្យមានវិវាទដែលមិនចាំបាច់កើតមាននៅចំពោះមុខ ស.ច.ស. ដែលអាចបើកសិទ្ធិឱ្យ ស.ព.អ. ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាំងនេះ ហើយសេចក្តីសម្រេចរបស់ ស.ច.ស. នឹងចាត់ទុកជាបានការ ក្រោយ អ.ប.ជ. ខកខានមិនអាចរកសំឡេងភាគច្រើនលើសលុប។

៦៩. ដោយការពិចារណាថា លោក មាស មុត មានសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើគ្នា ដោយការពិចារណាថាពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលសុពលនៅក្នុងរឿងក្តី ០០៣ (ដូចនៅក្នុងរឿងក្តី ០០៤/២) ដោយការពិចារណាថាពុំមានហេតុផលច្បាស់លាស់ ដើម្បីងាកចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ និង ដោយការពិចារណាថា ស.ច.ស. ពិចារណាថា រឿងក្តី ០០៣ ទុំជោរដល់ពេលត្រូវបញ្ចប់ (ដោយសារពុំមានអង្គហេតុ ឬ អង្គច្បាប់ថ្មី) ហេតុដូច្នេះ រាល់សំណើរបស់ ស.ព.អ. ដែលមិនស្របតាមការស្នើឡើងរបស់ ស.ច.ស. សុំ*បញ្ចប់* រឿងក្តី ០០៣ គួរត្រូវចាត់ទុកថា មិនអាចទទួលយកបាន និង/ឬ ប្រហាក់ប្រហែលនឹងគឺគួរត្រូវច្រានចោលតាមភាពពិតជាក់ស្តែង[197]។

---

[195] *ដូចខាងលើ* កថាខណ្ឌ ៦។

[196] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៤។

[197] សាលដីកាក្នុងរឿងក្តី ០០១ កថាខណ្ឌ ២០។ *សូមមើលផងដែរ រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៤៧ & ៤៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ឯកសារលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១០ និង ដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១០ ឯកសារ D250/3/2/1/5 កថាខណ្ឌ ២២។

## IV. សេចក្ដីសន្និដ្ឋាន និង សំណើដែលស្នើសុំ

៧០. លោក មាស មុត អាយុ ៨២ ឆ្នាំ[198]។ អស់រយៈពេល ១៣ ឆ្នាំ មកហើយ ដែលគាត់បានរស់នៅក្រោមទម្ងន់ និង ការមាក់ងាយជាសាធារណៈថា គាត់កំពុងស្ថិតក្រោមការស៊ើបអង្កេតពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មជាតិ ដោយគ្មានចម្លើយច្បាស់លាស់ថា តើគាត់នឹងប្រឈមការជំនុំជម្រះក្ដីដែរឬទេ។ ៤៣ ឆ្នាំ បន្ទាប់ពីព្រឹត្តិការណ៍នៅក្នុងរឿងក្ដី ០០៣ ដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់នៅរង់ចាំការសម្រេច ដោយបំបែកជាពីរផ្នែកក្នុងផ្លូវតុលាការរបស់ អ.ប.ជ. ដែលចចេសប្រកាន់ខ្ជាប់គោលជំហរផ្ទុយគ្នា ដែលនាំឱ្យប៉ះពាល់ដល់បទដ្ឋានអន្តរជាតិ ដែល អ.វ.ត.ក. ត្រូវគោរពតាមយ៉ាងខ្ជាប់ខ្ជួន ដោយមិនអាចសម្រុះសម្រួលបាន។ ជាមួយនឹងពេលវេលាកន្លងផុត ការរសាយការចងចាំ និង ការបាត់បង់ភស្តុតាង[199] ការរំពឹងទុកនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ចំពោះលោក មាស មុត កំពុងរលាយបាត់បណ្ដើរៗ កុំថាឡើយការជួយដល់ការស្វែងរកការពិតនោះ។

៧១. គួរឱ្យសោកស្ដាយ ដោយការបដិសេធមិនវៀរចាកពីឥរិយាបថជំហរមុនរបស់ខ្លួន ក្នុងការស៊ើបអង្កេតប្រកបដោយភាតរភាពលើរឿងក្ដីនេះ ឬ ចេញដីកាដំណោះស្រាយមួយដែលកែប្រែ និង ដោយការព្រានចោលការសម្រេចលើអង្គច្បាប់របស់អង្គជំនុំជម្រះតុលាការកំពូល និង ដោយការចេញសេចក្ដីពិចារណាផ្ទុយគ្នាដាច់ដោយឡែកពីគ្នា ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. កំពុងថ្កោលទោស លោក មាស មុត ឱ្យប្រឈមនឹងអសច្ចភាព ដំណើរការនីតិវិធីវិលវល់ ស្ថានការណ៍លំបាក ដូចជនត្រូវចោទ អោ អាន ក្នុងរឿងក្ដី ០០៤/២ ដែល ប៉ុន្តែ ការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល (ចំពោះចៅក្រមអន្តរជាតិបានស្ដីបន្ទោស) នឹងនៅតែស្ថិតក្នុងការជាប់គាំងផ្នែកច្បាប់ ប៉ុន្តែនៅអលទ្ធភាពនៃដំណើរការត្រឹមត្រូវនៅឡើយ ដែលបន្តឱ្យមានការភ័យខ្លាចខាងផ្លូវចិត្ត និង ការមាក់ងាយនៅក្នុងសង្គម ដោយសារមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅតាមលងបន្លាចគាត់។

៧២. ឥឡូវ ដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវចាត់ការឱ្យដាច់ស្រេច។ ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិអំណាច ជាភារកិច្ចពិត ដើម្បីរារាំងមិនឱ្យមានការលោភបំពានបន្ត

---

[198] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174។

[199] *សូមមើល ស្ថានភាពនៅក្នុងប្រទេសភូមា* សំណុំរឿងលេខ ICC-RoC46(3)-01/18-37 សេចក្ដីសម្រេចលើ "សំណើរបស់រដ្ឋអាជ្ញាសម្រាប់ការសម្រេចលើបញ្ហាយុត្តាធិការ មាត្រា ១៩(៣) នៃលក្ខន្តិក" ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៨ កថាខណ្ឌ ញ៨៦។

ទៀតលើសិទ្ធិទទួលមានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក មាស មុត និង ដើម្បីអភិរក្ស សុចរិតភាពនៃកេរដំណែលរបស់ អ.វ.ត.ក. ដោយការបញ្ចប់រឿងក្តី ០០៣ ស្របតាមសេចក្តីសម្រេចរបស់ពួកគាត់ក្នុងរឿងក្តី ០០៤/២។ ចំណាត់ការណាមួយផ្សេងពីនេះ គឺជាការរំលោភលើសិទ្ធិរបស់ លោក មាស មុត ក្នុងការទទួលបានការប្រព្រឹត្តដោយស្មើភាព ដោយការផ្លាស់ប្តូរទំនួលខុសត្រូវទៅ ស.ច.ស. ក្នុងការបញ្ចប់រឿងក្តី ០០៣។

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានជម្រាបជូនខាងលើនេះ មេធាវីការពារក្តីគោរពស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក. **ទទួលយក** សំណើនេះ។

ខ. **បញ្ចប់** សំណុំរឿង ០០៣។ និង

គ.**បង្គាប់** ឱ្យ ស.ច.ស. ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៤** ខែ**តុលា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

អាង ឧត្តម | Michael G. KARNAVA